# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១៦-៦-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦០៤ ស្តីពី ការតែងតាំង និងផ្តល់ឋានៈ ជូនឯកឧត្តម សាស្ត្រាចារ្យ François Xavier-Roux ជាទីប្រឹក្សាក្រសួងសុខាភិបាល មានឋានៈស្មើ អនុរដ្ឋលេខាធិការ ៥៤៤៩

១៦-៦-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦០៥ ស្តីពី ការតែងតាំងមុខតំណែង ឯកឧត្តម **ស៊ីន សុជា** ជា អគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការទូទៅ នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ៥៤៥០

១៦-៦-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦០៦ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ដល់ នាយទាហាន ថ្នាក់ឧត្តមសេនីយ៍ និងថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ចំនួន ០៥ រូប ៥៤៥១

១៦-៦-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦០៧ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ ដល់សពលោក **ហួ ហ៊ាប** នៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ ៥៤៥២

១៦-៦-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦០៨ ស្តីពីការបញ្ចប់មុខតំណែងឯកឧត្តម **ម៉ៅ ម៉ុននាង** ពីសមាជិកក្រុមលេខាសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អគ្គនាយក ៥៤៥៣

១៦-៦-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦០៩ ស្តីពី ការដាក់ឱ្យចូលនិវត្តន៍នាយនគរបាលថ្នាក់ ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ២៧ រូប ៥៤៥៤

១៦-៦-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦១០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម អស់លោក និងលោកស្រី ចំនួន ៦០ រូប ៥៤៥៦

១៦-៦-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦១១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឧកញ៉ា និងកងកម្លាំងប្រដាប់អាវុធ ចំនួន ២១១ រូប ៥៤៥៨

១៦-៦-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦១២ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់អ្នកស្រី **ស៊ុន ធីងធីង** (SUN TINGTING) ជនជាតិចិន សញ្ជាតិចិន ៥៤៦៥

១៦-៦-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៦១៦/៦១៣ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **សេង តឺហេង** (TSENG TE-HENG ) ជនជាតិចិនតៃវ៉ាន់ សញ្ជាតិចិនតៃវ៉ាន់ ៥៤៦៦

## II-រាជរដ្ឋាភិបាល

### ១- អនុក្រឹត្យ

១៧-៦-២០១៦ -អនុក្រឹត្យលេខ ១២៦ អនក្រ.បក ស្តីពី ការបង្កើតគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ សម្រាប់ការពារការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ ២០១៦ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតថ្នាក់ជាតិ-ថ្នាក់ក្រោមជាតិ ចាប់ពីឆ្នាំ ២០១៦ ដល់ឆ្នាំ ២០១៩ ៥៤៦៧

២២-៦-២០១៦ -អនុក្រឹត្យលេខ ១២៨ អនក្រ.បក ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់វេទិកាសម្ព័ន្ធសង្គមស៊ីវិល ៥៤៧១

១៥-៦-២០១៦ -អនុក្រឹត្យលេខ ៦៥៩ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា ៥៤៧៤

១៦-៦-២០១៦ -អនុក្រឹត្យលេខ ៦៦០ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីការទូតជាន់ខ្ពស់ ៥៤៧៥

១៦-៦-២០១៦ -អនុក្រឹត្យលេខ ៦៦១ អនក្រ.តត ស្តីពី ការបញ្ចប់អាណត្តិបេសកកម្មមន្ត្រីការទូតជាន់ខ្ពស់ ៥៤៧៧

១៦-៦-២០១៦ -អនុក្រឹត្យលេខ ៦៦២ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៥៤៧៩

១៦-៦-២០១៦ -អនុក្រឹត្យលេខ ៦៦៣ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា ៥៤៨១

១៦-៦-២០១៦ -អនុក្រឹត្យលេខ ៦៦៤ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ៥៤៨៣

១៧-៦-២០១៦ -អនុក្រឹត្យលេខ ៦៦៥ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥៤៨៤

១៧-៦-២០១៦ -អនុក្រឹត្យលេខ ៦៦៦ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៥៤៨៦

១៧-៦-២០១៦ -អនុក្រឹត្យលេខ ៦៦៧ អនក្រ.តត ស្តីពី ការតែងតាំងមុខតំណែង និងតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា ៥៤៨៨

១៧-៦-២០១៦ -អនុក្រឹត្យលេខ ៦៦៨ អនក្រ.តត ស្តីពី ការផ្ទេរសម្រួលភារកិច្ចមន្ត្រីរាជការ ៥៤៩០

២០-៦-២០១៦ -អនុក្រឹត្យលេខ ៦៦៩ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៥៤៩១

## ២-សេចក្ដីសម្រេច

២២-៦-២០១៦ -សេចក្ដីសម្រេចលេខ ៥៩ សសរ ស្ដីពី ការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីសម្របសម្រួលរៀបចំខ្លឹមសារសម្រាប់កិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃលើកទី ៦ ៥៤៩២

២២-៦-២០១៦ -សេចក្ដីសម្រេចលេខ ៦០ សសរ ស្ដីពី ការបង្កើតគណៈកម្មាធិការសម្របសម្រួលអន្តរក្រសួងគ្រប់គ្រង និងត្រួតពិនិត្យទំនិញគ្រោះថ្នាក់ ៥៤៩៥

២៤-៦-២០១៦ -សេចក្ដីសម្រេចលេខ ៦១ សសរ ស្ដីពី ការតែងតាំងទីប្រឹក្សាសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ៥៤៩៩

## III-ការងារបណ្ដាក្រសួង

## ១-ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

៣១-៣-២០១៦ -ប្រកាសលេខ ៣៣៧ សហវ.ប្រក ស្ដីពី បែបបទ និងនីតិវិធីចំណាយលើការងារអន្តរាគមន៍ជួសជុលបន្ទាន់ផ្លូវជនបទ ស្ពាន និងលូ ៥៥០១

០៤-៤-២០១៦ -ប្រកាសលេខ ៣៤១ សហវ.ប្រក ស្ដីពី ការបង្កើតរជ្ជទេយ្យបុរេប្រទាន សម្រាប់ឆ្នាំ ២០១៦ របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ៥៥០៤

០៤-៤-២០១៦ -ប្រកាសអន្តរក្រសួងលេខ ៣៤៦ សហវ.ប្រក ស្ដីពី ការបង្កើតរជ្ជទេយ្យបុរេប្រទាន សម្រាប់ឆ្នាំ ២០១៦ របស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ៥៥១០

០៤-៤-២០១៦ -ប្រកាសលេខ ៤២០ សហវ.ប្រក ស្ដីពី ការបង្កើតរជ្ជទេយ្យបុរេប្រទាន សម្រាប់ឆ្នាំ ២០១៦ របស់ឧត្ដមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ៥៥១៤

០៤-៤-២០១៦ -ប្រកាសលេខ ៤២១ សហវ.ប្រក ស្ដីពី ការបង្កើតរជ្ជទេយ្យបុរេប្រទាន សម្រាប់ឆ្នាំ ២០១៦ របស់វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៥៥២០

០៤-៤-២០១៦ -ប្រកាសលេខ ៤៣២ សហវ.ប្រក ស្ដីពី ការបង្កើតរជ្ជទេយ្យបុរេប្រទាន សម្រាប់ឆ្នាំ ២០១៦ របស់អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ ៥៥២៦

០៤-៤-២០១៦ -ប្រកាសលេខ ៤៣៣ សហវ. អវ ស្ដីពី ការបង្កើតរជ្ជទេយ្យបុរេប្រទាន សម្រាប់ឆ្នាំ ២០១៦ របស់អគ្គនាយកដ្ឋានថវិកា ៥៥៣២

០៤-៤-២០១៦ -ប្រកាសអន្តរក្រសួងលេខ ៤៣៦ សហវ.ប្រក ស្ដីពី ការបង្កើតរជ្ជទេយ្យបុរេប្រទាន សម្រាប់ឆ្នាំ ២០១៦ របស់សាកលវិទ្យាល័យបាត់ដំបង ៥៥៣៨

០៤-៤-២០១៦ -ប្រកាសលេខ ៤៣៧ សហវ.ប្រក ស្តីពី ការបង្កើតរជ្ជទេយ្យបុរេប្រទាន សម្រាប់ឆ្នាំ ២០១៦ របស់អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ៥៥៤៣

០៤-៤-២០១៦ -ប្រកាសលេខ ៤៥៨ សហវ.ប្រក ស្តីពី ការលុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌ ៥៥៤៨

០៤-៤-២០១៦ -ប្រកាសលេខ ៤៦៣ សហវ.ប្រក ស្តីពី ការលុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌ ៥៥៥០

០៤-៤-២០១៦ -ប្រកាសអន្តរក្រសួងលេខ ៤៦៦ សហវ.ប្រក ស្តីពី ការតែងតាំងភ្នាក់ងារបើកផ្តល់សម្រាប់ឆ្នាំ ២០១៦ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ៥៥៥២

០៤-៤-២០១៦ -ប្រកាសអន្តរក្រសួងលេខ ៤៦៧ សហវ.ប្រក ស្តីពី ការបង្កើតរជ្ជទេយ្យបុរេប្រទាន សម្រាប់ឆ្នាំ ២០១៦ របស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា (ក្រសួងធនធានទឹក និងឧតុនិយម) ៥៥៥៤

០៤-៤-២០១៦ -ប្រកាសអន្តរក្រសួងលេខ ៤៦៨ សហវ.ប្រក ស្តីពី ការតែងតាំងភ្នាក់ងារបើកផ្តល់សម្រាប់បើកប្រាក់បៀវត្សរ៍ និងប្រាក់អន្តរាគមន៍ ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌ ជូនមន្ត្រីរាជការនៅក្រសួងមហាផ្ទៃ ផ្នែករដ្ឋបាលទូទៅ ៥៥៥៧

០៤-៤-២០១៦ -ប្រកាសអន្តរក្រសួងលេខ ៤៦៩ សហវ.ប្រក ស្តីពី ការតែងតាំងរជ្ជទេយ្យករបុរេប្រទាន របស់ក្រសួងមហាផ្ទៃ ផ្នែករដ្ឋបាលទូទៅ ៥៥៥៩

## ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និង សិប្បកម្ម

១៥-៣-២០១៦ -ប្រកាសលេខ ១៨៤ ឧស.កឧ.ប្រក.០៣ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ូ ហ្គោល លីត ហូលឌីង បង្កើតរោងចក្រ ផលិតគ្រឿងបន្ទំស្បែកជើង ៥៥៦១

១៥-៣-២០១៦ -ប្រកាសលេខ ១៨៥ ឧស.កឧ.ប្រក.០៣ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន មីលេនៀម អេកសេសឺរី មេញូហ្វេកឈ័រ បង្កើតរោងចក្រ ផលិតគ្រឿងបន្ទំសម្លៀកបំពាក់ ៥៥៦៤

## ៣-ទីស្តីការរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

១៥-៦-២០១៦ - ប្រកាសអន្តរក្រសួងលេខ ១៥៩ ប្រក/ដនស.ម.ផ ស្តីពី ការកែសម្រួលប្រការ ៩ នៃប្រកាស អន្តរក្រសួងលេខ ២១៥ ប្រក/ដនស.មផ ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៥ ស្តីពី តួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ សង្កាត់ ក្នុងការចុះបញ្ជីដីធ្លី ៥៥៦៧

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៦/៦០៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រី ដែលមានឋានៈស្មើ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំង និងផ្តល់ឋានៈ ជូនឯកឧត្តមសាស្ត្រាចារ្យ François Xavier-Roux ជាទីប្រឹក្សាក្រសួងសុខាភិបាល មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចារឈ. ១៦០៦.៦១១

លេខៈ៦០៦ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៦*

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៦/៦០៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងមុខតំណែង ឯកឧត្តម **ស៊ីន សុវិថា** ជា អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**មាត្រា២:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៧រស.១៦០៦.៦១៥

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៦*

លេខ: ៦០៤ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៦/៦០៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តម្លើងឋានន្តរស័ក្តិ ដល់ នាយទាហាន ថ្នាក់ឧត្តមសេនីយ៍ និងថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ៖

**ក-ឋានន្តរស័ក្តិឧត្តមសេនីយ៍ទោ**

| | | | |
|---|---|---|---|
| ១-ឧត្តមសេនីយ៍ត្រី | **គីន** | **ផល្លា** | អត្តលេខ ២១៤០៦២ |
| ២-ឧត្តមសេនីយ៍ត្រី | **សេង** | **កុកហ៊ាង** | អត្តលេខ ២៣១៧០២ |

**ខ-ឋានន្តរស័ក្តិឧត្តមសេនីយ៍ត្រី**

| | | | |
|---|---|---|---|
| ១-វរសេនីយ៍ឯក | **លឹម** | **ហ្សូរនីតា** | អត្តលេខ ១៩៨៤១៧ |
| ២-វរសេនីយ៍ឯក | **គួង** | **អឿន** | អត្តលេខ ០០៣៣៨៤ |
| ៣-វរសេនីយ៍ឯក | **ម៉ក់** | **សំអូន** | អត្តលេខ ០០០៦៦៤ |

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

[illegible]. ១៦០៦.៦១៣

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៦*

លេខ: ៦០៧ ស.ណ
**សំណៅចែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៦/៦០៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៣/៨៩២ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៣ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តម្លើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ ដល់សពលោក **ឃួ ហ៊ាច** អត្តលេខ ១៤២៦ ពីឋានន្តរស័ក្តិ ឧត្តមអគ្គានុរក្ស ថ្នាក់លេខ៣ មកជា ឧត្តមអគ្គានុរក្ស ថ្នាក់លេខ២ នៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៧ភស.១៦០៦.៦១៤

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៦*

លេខៈ ៦០៥ ស.ណ
**សំណៅចម្លងចេញពីច្បាប់ដើម ដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៦/៦០៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រី ដែលមាន ឋានៈស្មើ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : បញ្ចប់មុខតំណែងឯកឧត្តម **ម៉ៅ ម៉ិននាង** ពីសមាជិកក្រុមលេខាសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អគ្គនាយក ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣រស.១៦០៦.៦១៥

លេខៈ ៦០៤ ស.ណ

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៦*

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែមិថុនា ឆ្នាំ២០១៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

នស/រកត/០៦១៦/៦០៩

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ /០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស  / រកត / ០៥០១ / ១៧៨ ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៦១០ / ៤៦៤ ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១០ ស្តីពីការកែសម្រួលមាត្រា៣៥ នៃព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។

## ត្រាស់បង្គាប់

**មាត្រា ១** : ដាក់ឱ្យចូលនិវត្តន៍នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ២៧ រូប :

| | | | |
|---|---|---|---|
| ១- នាយឧត្តមសេនីយ៍ | **ថុង ចន់** | អត្តលេខ | ០០៩ |
| ២- នាយឧត្តមសេនីយ៍ | **ខៀវ សុភ័គ** | អត្តលេខ | ០០៧២ |
| ៣- នាយឧត្តមសេនីយ៍ | **ចាន់ អ៊ាន** | អត្តលេខ | ០០២៤ |
| ៤- ឧត្តមសេនីយ៍ឯក | **គីម នាន** | អត្តលេខ | ០៣៥០ |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

| | | | |
|---|---|---|---|
| ៥- ឧត្តមសេនីយ៍ឯក | **អ៊ុន សុគន្ធា** | អត្តលេខ | ០២៥៩ |
| ៦- ឧត្តមសេនីយ៍ឯក | **រស់ សារិទ្ធ** | អត្តលេខ | ០១៥២ |
| ៧- ឧត្តមសេនីយ៍ឯក | **នៅ លក្ខណា** | អត្តលេខ | ០៤៣២ |
| ៨- ឧត្តមសេនីយ៍ឯក | **ប៉ូលី ជា** | អត្តលេខ | ០០៦៩ |
| ៩- ឧត្តមសេនីយ៍ឯក | **រស់ នីមសារុន** | អត្តលេខ | ០៤០៥ |
| ១០- ឧត្តមសេនីយ៍ឯក | **សួស សុខុន** | អត្តលេខ | ២១៥១ |
| ១១- ឧត្តមសេនីយ៍ឯក | **ឆាយ សាម៉េត** | អត្តលេខ | ០៧៩៣ |
| ១២- ឧត្តមសេនីយ៍ទោ | **នាក់ ឌីឡែន** | អត្តលេខ | ០២២៦ |
| ១៣- ឧត្តមសេនីយ៍ទោ | **ហេង ចាន់ថា** | អត្តលេខ | ០៤១៤ |
| ១៤- ឧត្តមសេនីយ៍ទោ | **រស់ សារឹម** | អត្តលេខ | ៧៥៥៩ |
| ១៥- ឧត្តមសេនីយ៍ទោ | **សាយ ឡោ** | អត្តលេខ | ០២៨៤ |
| ១៦- ឧត្តមសេនីយ៍ទោ | **ឈរុប ផន** | អត្តលេខ | ០៧២៦ |
| ១៧- ឧត្តមសេនីយ៍ទោ | **អ៊ុំ ម៉ុង** | អត្តលេខ | ០២៨៨ |
| ១៨- ឧត្តមសេនីយ៍ទោ | **ឈាង គីមស៊ុន** | អត្តលេខ | ០៨១៣ |
| ១៩- ឧត្តមសេនីយ៍ទោ | **លុក លន** | អត្តលេខ | ៣៦២៥ |
| ២០- ឧត្តមសេនីយ៍ទោ | **ស៊ុំ សាម៉េត** | អត្តលេខ | ០៣២២ |
| ២១- ឧត្តមសេនីយ៍ត្រី | **យាង ឯក** | អត្តលេខ | ០៥៩០ |
| ២២- ឧត្តមសេនីយ៍ត្រី | **ពេជ្រ សង្វាត** | អត្តលេខ | ០៣១៨ |
| ២៣- ឧត្តមសេនីយ៍ត្រី | **មិន សុផាត** | អត្តលេខ | ២១៧២ |
| ២៤- ឧត្តមសេនីយ៍ត្រី | **រ័ត្ន សារ៉ែន** | អត្តលេខ | ៤២២៥ |
| ២៥- ឧត្តមសេនីយ៍ត្រី | **ជ្រិន នារី** | អត្តលេខ | ៤៧៨៨ |
| ២៦- ឧត្តមសេនីយ៍ត្រី | **ភោគ ផាន្នី** | អត្តលេខ | ០៧៨៣ |
| ២៧- ឧត្តមសេនីយ៍ត្រី | **កែវ ប៊ុនសាង** | អត្តលេខ | ០២៧៦ ។ |

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

លេខៈ ៦០៨ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០១៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

៧២ល.១៦០៦.៦១៦

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៦*

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៦/៦១០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ប្រោសព្រះរាជទាន**

**ទូវ**

**ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១- ឯកឧត្តម **គុណ ញឹម**
២- លោក **ង៉ែមឃិន ធរៈ**
៣- លោក **ប៉ែន សំអាត**
៤- លោក **នួន ច័ន្ទរិទ្ធ**
៥- លោក **ហ៊ុច គីមហេង**

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :**

១- លោក **ខៀវ សំអាន**
២- លោកស្រី **ហេង សំអូន**
៣- លោក **ផា អេងម៉េង**
៤- លោក **កើត សុធ្វារ៉ា**
៥- លោក **ឆ បូណារី**
៦- លោក **កែវ សុខឃាង**

**គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :**

១- លោក **ង៉ាង ម៉ាន់ថន**
២- លោក **ឃុន វ៉ាន់**
៣- លោក **ង៉ាង ម៉ាន់ថា**
៤- លោក **ប៊ុត ប៊ិន**
៥- លោក **សុខ ទ្រី**
៦- លោក **គាំ ច័ន្ទកុសល**
៧- លោក **ប្រាក់ សូម៉េត**
៨- លោក **ដួង ប៊ូលីន**
៩- លោក **សុខ សុវិឌ្ឍា**
១០- លោក **ប៊ូរ ប៊ុនណារ៉ា**
១១- លោក **ស្រង់ ស៊ុណាវិទ្យ**
១២- លោក **សង់ សិទ្ធានិត្យ**
១៣- លោក **ឡុញ វណ្ណៈ**
១៤- លោក **ម៉ុក ហួត**
១៥- លោក **ម៉ៅ សួន**
១៦- លោក **ស្រេង សិណាង**
១៧- លោក **រស់ ដារ៉ា**
១៨- លោក **វង្ស សារ៉ាន់**
១៩- លោក **តិច សៀកចន**
២០- លោក **ថេង ម៉ុងហាក់**

ROYAUME DU CAMBODGE
ព្រះបរមរាជវាំង
LE MINISTRE DU PALAIS ROYAL

២១- លោក ឈយន ទឿន
២២- លោក ហួរ សុមេធ
២៣- លោក សៃ សុឃន
២៤- លោក គីម ខូន
២៥- លោក តិន សុតារក្ស
២៦- លោក ភួទ ណុច
២៧- លោក គិន លី
២៨- លោក ស៊ុន ឆាយ
២៩- លោក តេ សុមុនី
៣០- លោក យ៉ឹក យូ
៣១- លោក ស៊ុក គីមហេន
៣២- លោក កែវ ម៉ានី
៣៣- លោក ទ៉ូ វណ្ណា
៣៤- លោក អាំង លាង
៣៥- លោក ខៀវ សារឿន
៣៦- លោក ប្រាក់ ចាន់ធី
៣៧- លោក នូ ស៊ីថា
៣៨- លោក នាង វណ្ណា
៣៩- លោក ជួប ចំរើន
៤០- លោក ឆែ សុផា
៤១- លោក សុខ សុដារ៉ា
៤២- លោក យូ ហេង
៤៣- លោក ចាន់ សំបូរ
៤៤- លោក ថោង សុខាំត្យ
៤៥- លោក ឈុន សុភមង្គល
៤៦- លោក ទុំ ណូ
៤៧- លោក ម៉ាល ទូច
៤៨- លោក សំ សុខា
៤៩- លោក ហ៊ុច ពុទ្ធិរិទ្ធ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស.រកត.០៦១៦.៦១៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៦

លេខៈ ៦០១ ស.ណ
សំណៅចំលងមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ,ថ្ងៃទី ១៧ ខែមិថុនាឆ្នាំ២០១៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៦/៦៧៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

នូវ

**ក- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

| | | | |
|---|---|---|---|
| ១-ឧត្តមសេនីយ៍ត្រី | **ជា** | **ច័ន្ទត្រីស្នា** | អត្តលេខ០២៥៧០៤ |
| ២-វរសេនីយ៍ឯក | **ធៀម** | **ទេវរិទ្ធ** | អត្តលេខ០១៥២៩៧ |
| ៣-វរសេនីយ៍ឯក | **សេង** | **សាន** | អត្តលេខ០០៤៤២៣ |
| ៤-វរសេនីយ៍ឯក | **អ៊ុន** | **ទូច** | អត្តលេខ០១៩១៣៣ |
| ៥-វរសេនីយ៍ឯក | **អ៊ុក** | **អូន** | អត្តលេខ០១០០០៧ |
| ៦-វរសេនីយ៍ឯក | **ភួក** | **ច័ន្ទធូរ** | អត្តលេខ០១០០២២ |
| ៧-វរសេនីយ៍ឯក | **ស៊ឹម** | **រៀម** | អត្តលេខ០១៩១៣៧ |
| ៨-វរសេនីយ៍ឯក | **លិន** | **យន្ត** | អត្តលេខ០១០០១៣ |
| ៩-វរសេនីយ៍ឯក | **ភ្លយ** | **ពិសិដ្ឋ** | អត្តលេខ០១៩១២៧ |
| ១០-វរសេនីយ៍ឯក | **អ៊ុក** | **សាខន** | អត្តលេខ០១៩១០២ |
| ១១-វរសេនីយ៍ឯក | **ប៊ុត** | **ហុក** | អត្តលេខ០១០០១២ |
| ១២-វរសេនីយ៍ឯក | **ថាច់** | **សុវ៉ែន** | អត្តលេខ០១០០១១ |
| ១៣-វរសេនីយ៍ឯក | **មឿន** | **គង់** | អត្តលេខ០១៩០៦០ |
| ១៤-វរសេនីយ៍ឯក | **ប៉ែន** | **សាម៉េត** | អត្តលេខ០១៩១០៨ |
| ១៥-វរសេនីយ៍ឯក | **នួន** | **សុផល** | អត្តលេខ០១០០១០ |
| ១៦-វរសេនីយ៍ឯក | **ឆេង** | **យ៉ាន្នី** | អត្តលេខ០០២៩៧៧ |
| ១៧-វរសេនីយ៍ឯក | **ម៉ក់** | **សារ៉ុម** | អត្តលេខ០០៤៩០៤ |
| ១៨-វរសេនីយ៍ឯក | **សោម** | **ហួច** | អត្តលេខ០១៩១៨៤ |
| ១៩-វរសេនីយ៍ឯក | **អៀង** | **គី** | អត្តលេខ០០៤៩៨៣ |
| ២០-វរសេនីយ៍ឯក | **ហាឡ** | **សុផន** | អត្តលេខ០១០០១៥ |

ROYAUME du CAMBODGE • LE MINISTRE du PALAIS ROYAL

| | | | |
|---|---|---|---|
| ២១-វរសេនីយ៍ឯក | ខឡ្យ | កុសល | អត្តលេខ០០៤២០២ |
| ២២-វរសេនីយ៍ទោ | អ៊ឹម | ផល្លា | អត្តលេខ០២៩៧១៣ |
| ២៣-វរសេនីយ៍ទោ | ស្វ | សារិន | អត្តលេខ០១៧៧៤៧ |
| ២៤-វរសេនីយ៍ទោ | ឈុំ | សាមឿន | អត្តលេខ០១៩១១៥ |
| ២៥-វរសេនីយ៍ទោ | ព្រហ្ម | សារ៉ែន | អត្តលេខ០១០០២៥ |
| ២៦-វរសេនីយ៍ទោ | ភាន់ | ភៀន | អត្តលេខ០០៤៩៨២ |
| ២៧-វរសេនីយ៍ទោ | ទៀង | យុទ្ធហ៊ាន | អត្តលេខ០១៩១៤៣ |
| ២៨-វរសេនីយ៍ទោ | ស្វន | យក់ | អត្តលេខ០១៩១៤៧ |
| ២៩-វរសេនីយ៍ទោ | ហ៊ួន | ហ៊ាន | អត្តលេខ០១៩១៧២ |
| ៣០-វរសេនីយ៍ទោ | ឆាម | ឡាំ | អត្តលេខ០១០០៤៨ |
| ៣១-វរសេនីយ៍ទោ | កែវ | ហាន់ | អត្តលេខ០១០០៥២ |
| ៣២-វរសេនីយ៍ទោ | អ៊ិន | សារឿន | អត្តលេខ០១៩១៤២ |
| ៣៣-វរសេនីយ៍ទោ | ចាន់ | ជាន | អត្តលេខ០១០០៣៩ |
| ៣៤-វរសេនីយ៍ទោ | អ៊ួង | វិបុល | អត្តលេខ០១០០៤៥ |
| ៣៥-វរសេនីយ៍ទោ | ថុង | ឡុង | អត្តលេខ០១០០៤៧ |
| ៣៦-វរសេនីយ៍ទោ | គូ | ថន | អត្តលេខ០១០០៤១ |
| ៣៧-វរសេនីយ៍ទោ | ជុំ | ផាន | អត្តលេខ០០៤២០៤ |
| ៣៨-វរសេនីយ៍ទោ | កែម | ខុម | អត្តលេខ០០៤២០៥ |

**ខ- គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

| | | | |
|---|---|---|---|
| ១-ឧកញ៉ា | លឹម | ហេង | អគ្គនាយកក្រុមហ៊ុន លឹម ហេង គ្រុប |
| ២-ឧត្តមសេនីយ៍ទោ | សុខ | សាន្ត | អត្តលេខ០០០៣៨៨ |
| ៣-ឧត្តមសេនីយ៍ទោ | ស៊ុន | លីប | អត្តលេខ០០២៩៧២ |
| ៤-ឧត្តមសេនីយ៍ទោ | ឈាន | ឆន | អត្តលេខ០០១០០៤ |
| ៥-ឧត្តមសេនីយ៍ទោ | សៅ | កុសល | អត្តលេខ០០០៤០៦ |
| ៦-ឧត្តមសេនីយ៍ទោ | ភឿក | វេន | អត្តលេខ០០២៩៦៩ |
| ៧-ឧត្តមសេនីយ៍ទោ | វី | សុត្ថាវុទ្ធ | អត្តលេខ០០០៥៩៦ |
| ៨-ឧត្តមសេនីយ៍ទោ | ឱម | ហុង | អត្តលេខ០៣០៨៦៣ |
| ៩-ឧត្តមសេនីយ៍ទោ | សុខ | ឆារ៉ា | អត្តលេខ០៤៥៨៤០ |
| ១០-ឧត្តមសេនីយ៍ទោ | ព្រហ្ម | ពុធ | អត្តលេខ០០០៣៨៥ |
| ១១-ឧត្តមសេនីយ៍ត្រី | ប៊ុន | ច័ន្ទថា | អត្តលេខ០០៩៩៨៣ |
| ១២-ឧត្តមសេនីយ៍ត្រី | ខិន | ច័ន្ទ | អត្តលេខ០០០៩៨៣ |

**គ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :**

| | | | |
|---|---|---|---|
| ១-វរសេនីយ៍ឯក | ព្រិល | សាវី | អត្តលេខ០១៩៣៩៣ |

| | | | |
|---|---|---|---|
| ២-វរសេនីយ៍ឯក | អ៊ិត | សុខុម | អត្តលេខ០១៩០៦១ |
| ៣-វរសេនីយ៍ឯក | ជា | សុច្ច | អត្តលេខ១០២៦៧៣ |
| ៤-វរសេនីយ៍ឯក | ថោង | ឧុត្តា | អត្តលេខ០១៩១៤១ |
| ៥-វរសេនីយ៍ឯក | សុខ | សំអាត | អត្តលេខ១០២២៦៨ |
| ៦-វរសេនីយ៍ឯក | គីម | សុផាណា | អត្តលេខ០៧៥៩៨៨ |
| ៧-វរសេនីយ៍ទោ | តាំង | ឡេង | អត្តលេខ២៣២១២៦ |
| ៨-វរសេនីយ៍ទោ | ចាន់ | ថេង | អត្តលេខ១៣៤១៣៣ |
| ៩-វរសេនីយ៍ទោ | ទេព | សុផាន់ណា | អត្តលេខ០១២៥២៤ |
| ១០-វរសេនីយ៍ទោ | នៅ | ណាត | អត្តលេខ០២៩៦៧៧ |
| ១១-វរសេនីយ៍ទោ | មុត | ស៊ីថា | អត្តលេខ០២៤៤៨៦ |
| ១២-វរសេនីយ៍ទោ | យូ | វិបុល | អត្តលេខ០១២៦៤៥ |
| ១៣-វរសេនីយ៍ទោ | ម៉ូ | ណាល់ | អត្តលេខ០២៩៦២៩ |
| ១៤-វរសេនីយ៍ទោ | ហ៊ឹម | ណាល់ | អត្តលេខ១៥៦៦៣៥ |
| ១៥-វរសេនីយ៍ទោ | ពៅ | ពិសី | អត្តលេខ០២៩៦៣១ |
| ១៦-វរសេនីយ៍ទោ | សាយ | ខនថា | អត្តលេខ០១៩១៥៣ |
| ១៧-វរសេនីយ៍ទោ | ម៉ាន់ | វណ្ណះ | អត្តលេខ០១៩១១២ |
| ១៨-វរសេនីយ៍ទោ | លី | ដុន | អត្តលេខ០១៩១៣០ |
| ១៩-វរសេនីយ៍ទោ | ពាញ | សុផន | អត្តលេខ០១៩១៤៤ |
| ២០-វរសេនីយ៍ទោ | ហាង្ស | សារិន | អត្តលេខ១៥៧០០៩ |
| ២១-វរសេនីយ៍ទោ | អ៊ា | យ៉ាន | អត្តលេខ០៤១៦៨៣ |
| ២២-វរសេនីយ៍ទោ | ជិន | អ៊ុន | អត្តលេខ០២៩៦៦១ |
| ២៣-វរសេនីយ៍ទោ | ឌួន | សាឡឿន | អត្តលេខ០២៩៦៤១ |
| ២៤-វរសេនីយ៍ទោ | រស់ | ផល្លី | អត្តលេខ០២៦៨៧០ |
| ២៥-វរសេនីយ៍ទោ | ម៉ូ | សៀប | អត្តលេខ០១០០៣១ |
| ២៦-វរសេនីយ៍ទោ | យឹម | សុវណ្ណា | អត្តលេខ០១៩១២៥ |
| ២៧-វរសេនីយ៍ទោ | កែ | លន់ | អត្តលេខ០២៩៥០២ |
| ២៨-វរសេនីយ៍ទោ | អំ | សុផាន់ណា | អត្តលេខ១៥៦៨៦២ |
| ២៩-វរសេនីយ៍ទោ | ជុំ | ឈិន | អត្តលេខ០២៩៦៩២ |
| ៣០-វរសេនីយ៍ទោ | អ៊ុក | ចំរើន | អត្តលេខ០១៩១១៦ |
| ៣១-វរសេនីយ៍ទោ | ទុយ | ទួត | អត្តលេខ០១៩១៧៧ |
| ៣២-វរសេនីយ៍ទោ | សុខ | សោភា | អត្តលេខ០១៩១៦៦ |
| ៣៣-វរសេនីយ៍ទោ | ស៊ិន | ស្ងួន | អត្តលេខ០១៩១៦៧ |
| ៣៤-វរសេនីយ៍ទោ | ជីម | ទន | អត្តលេខ០១៩១៥៤ |




៣/៧

៣៥-វរសេនីយ៍ទោ ឆុយ ឈន អត្តលេខ០២៩៦៧៨
៣៦-វរសេនីយ៍ទោ សម អេម អត្តលេខ០៤១៧០៨
៣៧-វរសេនីយ៍ទោ អៀម សាឌុធ អត្តលេខ០២៩៦៩៣
៣៨-វរសេនីយ៍ទោ យ៉ែម សម័យ អត្តលេខ០១៩១៧៨
៣៩-វរសេនីយ៍ទោ ជួប សុភី អត្តលេខ០១៩១៨១
៤០-វរសេនីយ៍ទោ ទេស ខៀ្ន អត្តលេខ០១៩១៧៩
៤១-វរសេនីយ៍ទោ អេង គ្រី អត្តលេខ០២៩៧១២
៤២-វរសេនីយ៍ទោ មឿង គង់ អត្តលេខ០២៩៦៨១
៤៣-វរសេនីយ៍ទោ លេន ឌុង អត្តលេខ០២២៤៤៧
៤៤-វរសេនីយ៍ទោ នុត ឆាបចិជ្ជ័យ អត្តលេខ០២៩៦៤៩
៤៥-វរសេនីយ៍ទោ កែវ សារ៉ាន់ អត្តលេខ០១៩១៦៤
៤៦-វរសេនីយ៍ទោ ម៉ី ជួន អត្តលេខ០២៤៤៨៥
៤៧-វរសេនីយ៍ទោ ឆាង សុខុម អត្តលេខ០២៤៤៨៧
៤៨-វរសេនីយ៍ទោ សុខ ហួត អត្តលេខ០២៩៦៣៣
៤៩-វរសេនីយ៍ទោ នួន រដ្ឋា អត្តលេខ០២២៤៥០
៥០-វរសេនីយ៍ទោ ចាន់ បូរ៉ា អត្តលេខ០២៤១២៦
៥១-វរសេនីយ៍ត្រី ផៃ សុផាត អត្តលេខ០២៤៤៩១
៥២-វរសេនីយ៍ត្រី អៀម វាសនា អត្តលេខ០២៩៦៥០
៥៣-វរសេនីយ៍ត្រី យស ផល្លា អត្តលេខ០២៩៦៥៤
៥៤-វរសេនីយ៍ត្រី ភាន់ ស៊ាន អត្តលេខ១៥៦៧៦២
៥៥-វរសេនីយ៍ត្រី សោម សំអឿន អត្តលេខ០១៩១៤៦
៥៦-វរសេនីយ៍ត្រី ឈើយ វណ្ណា: អត្តលេខ០១៩១៤៥
៥៧-វរសេនីយ៍ត្រី ប្រាក់ ច័ន្ទតារា អត្តលេខ០៤១៦៧៣
៥៨-វរសេនីយ៍ត្រី ឈុន យឿន អត្តលេខ០១៩១៣៥
៥៩-វរសេនីយ៍ត្រី ពន់ ពៃ អត្តលេខ០១៩១៤៨
៦០-វរសេនីយ៍ត្រី ផុន ភី អត្តលេខ០១៩១៣៨
៦១-វរសេនីយ៍ត្រី ចក់ មឿក អត្តលេខ០៤១៦៧៦
៦២-វរសេនីយ៍ត្រី ខៀវ ចាន់រស្មី អត្តលេខ០១៩១២២
៦៣-វរសេនីយ៍ត្រី ពៅ វិចិត្រ អត្តលេខ០១៩១៤៩
៦៤-វរសេនីយ៍ត្រី លឹម សូត្រ អត្តលេខ០២៩៦៩០
៦៥-វរសេនីយ៍ត្រី ហឿង សុជាតិ អត្តលេខ០១៩១៧៤
៦៦-វរសេនីយ៍ត្រី គីម វរៈ អត្តលេខ០២៩៧០៨
៦៧-វរសេនីយ៍ត្រី ចាន់ សារី អត្តលេខ០១០០៥៣

៦៨-វរសេនីយ៍ត្រី ច្រាក់ ម៉ុនលី អត្តលេខ០២៩៧២៨
៦៩-វរសេនីយ៍ត្រី គាំ ជីវ៉ា អត្តលេខ០១០០៥១
៧០-វរសេនីយ៍ត្រី អ៊ុច ឈឿប អត្តលេខ០១៩២០៤
៧១-វរសេនីយ៍ត្រី ឆ្មា គុត អត្តលេខ០២២៤៥១
៧២-វរសេនីយ៍ត្រី ឈិម សេត អត្តលេខ០១៩១៧៥

**ឃ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា :**

១-វរសេនីយ៍ឯក យូច ស៊ីផា អត្តលេខ០១០០០៩
២-វរសេនីយ៍ឯក រ័ត្ន ស៊ីថា អត្តលេខ០១០០១៨
៣-វរសេនីយ៍ឯក ហំ ចាន់បូរ អត្តលេខ០១០០២៤
៤-វរសេនីយ៍ឯក ទេព គត់ អត្តលេខ០០៤២០៣
៥-វរសេនីយ៍ឯក គ្លំ ម៉ុនរឿន អត្តលេខ០១០០០៨

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :**

១-វរសេនីយ៍ឯក យ៉ុង ម៉ឿន អត្តលេខ០១៩១៩៥
២-វរសេនីយ៍ឯក តែន សារិទ្ធ អត្តលេខ០០១៥៣៧
៣-វរសេនីយ៍ឯក សាត សម៉េង អត្តលេខ០០៨៤៦៧
៤-វរសេនីយ៍ទោ នួន ម៉ុនថារីន អត្តលេខ០៤៣១១៥
៥-វរសេនីយ៍ទោ ផុន សុគា អត្តលេខ០១៤៣១៦
៦-វរសេនីយ៍ទោ តាជ សំបូរ អត្តលេខ១៥៦៩១៣
៧-វរសេនីយ៍ទោ ព្រីង សំអូន អត្តលេខ០១៩១៩៥
៨-វរសេនីយ៍ទោ ស៊ិន វណ្ណៈ អត្តលេខ០៤១៦៧៩
៩-វរសេនីយ៍ទោ ហៃ ស៊ីត អត្តលេខ០៤១៧៥៦
១០-វរសេនីយ៍ទោ គី សុគាព អត្តលេខ០២៩៧៣៩
១១-វរសេនីយ៍ទោ ស៊ុន រ៉ែន អត្តលេខ០២៩៦៣២
១២-វរសេនីយ៍ទោ ឈឹម សុគ័ន្រ្ធ អត្តលេខ១៥៦៩៦១
១៣-វរសេនីយ៍ទោ ខាត់ វិសាល អត្តលេខ០៤៧១៤១
១៤-វរសេនីយ៍ទោ ទុំ ជី អត្តលេខ០២៩៧១១
១៥-វរសេនីយ៍ទោ អន ចាន់ណា អត្តលេខ១៥៨៨៣៣
១៦-វរសេនីយ៍ត្រី តោក ម៉ិន អត្តលេខ១៥៦៦៣៣
១៧-វរសេនីយ៍ត្រី ពៅ សំណាង អត្តលេខ០២៩៦៧១
១៨-វរសេនីយ៍ត្រី អ៊ិន ហៃ អត្តលេខ០២៩៦៦៥
១៩-វរសេនីយ៍ត្រី សោក ឡើន អត្តលេខ០៤១៦៧៨
២០-វរសេនីយ៍ត្រី សាក់ ណាក់ អត្តលេខ១៥៦៧៧៧
២១-វរសេនីយ៍ត្រី មាស សំណាង អត្តលេខ០២៦៨៦០
២២-វរសេនីយ៍ត្រី សុត ណេន អត្តលេខ០២៩៥០៧
២៣-វរសេនីយ៍ត្រី ជិន រ៉ុន អត្តលេខ០៥០៥៩៨
២៤-វរសេនីយ៍ត្រី សួង ឡោត អត្តលេខ០៤១៦៨៧
២៥-វរសេនីយ៍ត្រី អ៊ុង សុខា អត្តលេខ១៥៦៩៣៦

| | | | |
|---|---|---|---|
| ២៦-វរសេនីយ៍ត្រី | ហែម | ចំរើន | អត្តលេខ០៤១៧៣១ |
| ២៧-វរសេនីយ៍ត្រី | តិច | ប៊ុនលី | អត្តលេខ០២៩៧២៧ |
| ២៨-វរសេនីយ៍ត្រី | ថន | អៀម | អត្តលេខ០៤១៧៤៥ |
| ២៩-វរសេនីយ៍ត្រី | ស៊ឹម | រិទ្ធ | អត្តលេខ០៩១៣៤៧ |
| ៣០-វរសេនីយ៍ត្រី | កែវ | ឡម | អត្តលេខ០៣៣៤៤៥ |
| ៣១-វរសេនីយ៍ត្រី | ឌុធ | ធារី | អត្តលេខ០២៩៦៩១ |
| ៣២-វរសេនីយ៍ត្រី | នុត | គ្រែម | អត្តលេខ១៤៦៦៧៤ |
| ៣៣-វរសេនីយ៍ត្រី | សោម | សាឌុធ | អត្តលេខ០៦៤៧៨៣ |
| ៣៤-វរសេនីយ៍ត្រី | ជា | ណារាជ | អត្តលេខ០៥២៨១៣ |

ច-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :

| | | | |
|---|---|---|---|
| ១-វរសេនីយ៍ទោ | ឡុង | សុខខួន | អត្តលេខ០១៧៧៨៦ |
| ២-វរសេនីយ៍ទោ | មាស | ភួង | អត្តលេខ០៤៤៩៤៣ |
| ៣-វរសេនីយ៍ត្រី | ឃឹម | វ៉ាន់ថន | អត្តលេខ១៥៦៦៣៤ |
| ៤-វរសេនីយ៍ត្រី | នៅ | ណារុំ | អត្តលេខ០២២៤៤៩ |
| ៥-វរសេនីយ៍ត្រី | ញឹម | ពិសិដ្ឋ | អត្តលេខ០២៩៧៨១ |
| ៦-វរសេនីយ៍ត្រី | ម៉ែន | ណារិទ្ធ | អត្តលេខ០៤១៦៧២ |
| ៧-វរសេនីយ៍ត្រី | ព្រឿង | ពូន | អត្តលេខ១៥៦៦៧៤ |
| ៨-វរសេនីយ៍ត្រី | ហេង | ដាក | អត្តលេខ០២៩៦៦២ |
| ៩-វរសេនីយ៍ត្រី | ពុយ | សុជាតិ | អត្តលេខ០២៩៦៦០ |
| ១០-វរសេនីយ៍ត្រី | ប៊ុន | ហាន | អត្តលេខ០៤១៦៧៥ |
| ១១-វរសេនីយ៍ត្រី | ស៊ិន | សុផាន | អត្តលេខ០២៦៦៧៣ |
| ១២-វរសេនីយ៍ត្រី | មាន | ស៊ីផា | អត្តលេខ០២៩៦៤០ |
| ១៣-វរសេនីយ៍ត្រី | គៀម | រឿម | អត្តលេខ០២៩៦៩៦ |
| ១៤-វរសេនីយ៍ត្រី | ញ៉ា | សារ៉ែន | អត្តលេខ០២៩៦៩៤ |
| ១៥-វរសេនីយ៍ត្រី | ព្រឿង | ឌីន | អត្តលេខ០៦៤៦៣៦ |
| ១៦-វរសេនីយ៍ត្រី | ទឹម | ឆុន | អត្តលេខ០២៩៦៨០ |
| ១៧-វរសេនីយ៍ត្រី | សិ | ប៊ុនហៀក | អត្តលេខ០១៩១៦៥ |
| ១៨-វរសេនីយ៍ត្រី | យន្ត | សាមាន | អត្តលេខ០៤១៧១២ |
| ១៩-វរសេនីយ៍ត្រី | ជា | បឿន | អត្តលេខ០២៩៦៧៤ |
| ២០-វរសេនីយ៍ត្រី | សុខ | ឫទ្ធី | អត្តលេខ០៤១៧៥១ |
| ២១-វរសេនីយ៍ត្រី | អេង | ណុល | អត្តលេខ១៥៦៩៣៥ |

ឆ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ :

| | | | |
|---|---|---|---|
| ១-វរសេនីយ៍ទោ | អាន | សូរីដា | អត្តលេខ០២៤១៤៨ |
| ២-វរសេនីយ៍ទោ | អៀង | ស៊ីណាត | អត្តលេខ១៦៣១២១ |
| ៣-វរសេនីយ៍ទោ | ទៀប | សូផូ | អត្តលេខ០០៨៥១៥ |
| ៤-វរសេនីយ៍ទោ | សាន់ | គីមសាយ៉ា | អត្តលេខ១៣៨៨៣៨ |
| ៥-វរសេនីយ៍ត្រី | ឡោម | ចំរើន | អត្តលេខ០៨៦២៥១ |

| | | |
|---|---|---|
| ៦-វរសេនីយ៍ត្រី | ធឿន សុភា | អត្តលេខ០៣១៣២២ |
| ៧-វរសេនីយ៍ត្រី | ហួត សាត | អត្តលេខ១៥៦៦៤២ |
| ៨-វរសេនីយ៍ត្រី | អ៊ុំ សារ៉ែន | អត្តលេខ០២៩៧៣៤ |
| ៩-វរសេនីយ៍ត្រី | សែម សារ៉េត | អត្តលេខ០៥០៥៨៣ |
| ១០-វរសេនីយ៍ត្រី | ព្រហ្ម ឌីណា | អត្តលេខ១០២៨៧៨ |
| ១១-វរសេនីយ៍ត្រី | ស៊ាប ម៉េងស៊ាង | អត្តលេខ១០២៣០៤ |
| ១២-វរសេនីយ៍ត្រី | តិន ត៉ក្រ | អត្តលេខ១០២១៤៣ |
| ១៣-វរសេនីយ៍ត្រី | អ៊ុយ ប៊ុនធឿន | អត្តលេខ១៥៧០៣៣ |
| ១៤-វរសេនីយ៍ត្រី | ម៉ាញ ឧត្តម | អត្តលេខ០៨៦២១៩ |
| ១៥-វរសេនីយ៍ត្រី | ចាន់ ប៊ុនជឿន | អត្តលេខ១៥៦៦៥១ |
| ១៦-វរសេនីយ៍ត្រី | សេង ម៉េងឡុង | អត្តលេខ១០២៨៣៧ |
| ១៧-វរសេនីយ៍ត្រី | ភាន់ ចាន់រ៉ា | អត្តលេខ០៦៤៤៦៣ |
| ១៨-វរសេនីយ៍ត្រី | ហាម ប៊ុនធឿន | អត្តលេខ០៤៨៤៨៣ |
| ១៩-វរសេនីយ៍ត្រី | ឈុំ មុន្នីរ៉ា | អត្តលេខ១០៣៣៦១ |
| ២០-វរសេនីយ៍ត្រី | ឈឿន ហឿន | អត្តលេខ០២៩៦៤៣ |
| ២១-វរសេនីយ៍ត្រី | ពេជ្រ ជាហួត | អត្តលេខ១៥៦៦៦៦ |
| ២២-វរសេនីយ៍ត្រី | ម៉ន សារឹម | អត្តលេខ០៤១៧២៥ |
| ២៣-វរសេនីយ៍ត្រី | ចាន់ សារិន | អត្តលេខ០៤១៧២៧ |
| ២៤-វរសេនីយ៍ត្រី | មូល ម៉ាន់សក្តិ | អត្តលេខ០២៩៧០៥ |
| ២៥-វរសេនីយ៍ត្រី | ឈុំ តារម្យ | អត្តលេខ១៥៦៩៤២ |
| ២៦-វរសេនីយ៍ត្រី | ឌឹម រីន | អត្តលេខ១៥៦៩៥៩ |

**ជ-គ្រឿងឥស្សរិយយស សេនាជ័យសិទ្ធិ:**

| | | |
|---|---|---|
| ១-វរសេនីយ៍ឯក | ស រីណា | អត្តលេខ០១០០២១ |
| ២-វរសេនីយ៍ឯក | ហាម ប៊ុនហួត | អត្តលេខ០២៥៧០៣ |
| ៣-វរសេនីយ៍ឯក | សូ ម៉ៅ | អត្តលេខ០១០០៨៨ |

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចារស. ១៦០៦.៦១៨

លេខ: ៦០៣ ស.ណ

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៦

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៦/៦១៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតក្ខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់អ្នកស្រី **ស៊ុន ធីងធីង** (SUN TINGTING) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៨៩ នៅខេត្តហៃឡុងជាង សាធារណរដ្ឋប្រជាមានិតចិន។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ជករ**
**នរោត្តម សីហមុនី**

ចាវលៈ ១៦០៦.៦១៩

លេខៈ ៦០៩ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៦*

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០១៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

សយ សុខា

នស/រកត/០៦១៦/៦១៧

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ១០៩៦ / ៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **សេង តឺហេង** (TSENG TE-HENG) ជនជាតិចិនតៃវ៉ាន់ សញ្ជាតិចិនតៃវ៉ាន់ កើតថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ១៩៦២ នៅទីក្រុងតៃប៉ិ សាធារណរដ្ឋចិន។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៧៩លៈ ១៦០៦.៦២០

លេខៈ ៦១១ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៦*

រាជធានីភ្នំពេញ ,ថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ  សាសនា  ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ**១២៦..អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ សម្រាប់ការពារការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតថ្នាក់ជាតិ-ថ្នាក់ក្រោមជាតិ ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០២០ ចុះថ្ងៃទី ២០ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា
- បានឃើញព្រះរាជក្រមលេខ នស /រកម /០៣១៥ /០០៣ ចុះថ្ងៃទី ២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី ១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១ :** ត្រូវបានបង្កើតគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ អក្សរកាត់ គ.ស.អ សម្រាប់ការពារការចុះឈ្មោះបោះឆ្នោតដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ

និងការបោះឆ្នោតថ្នាក់ជាតិ-ថ្នាក់ក្រោមជាតិ ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩ ដែលមានសមាសភាព ដូចខាងក្រោម ៖

១. សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធាន

២. ឯកឧត្តម **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ អនុប្រធាន

៣. ឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៤. ឯកឧត្តម **វង សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក

៥. ឯកឧត្តម **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

៦. ឯកឧត្តម **ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម សមាជិក

៧. ឯកឧត្តម **សុខ ចិន្តា** អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

៨. ឯកឧត្តម **ឯម សំអាន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក

៩. ឯកឧត្តម **ចាយ សាំងយុន** រដ្ឋលេខាធិការក្រសួងការពារជាតិ សមាជិក

១០.ឯកឧត្តមនាយឧត្តមសេនីយ៍ **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ សមាជិក

១១.ឯកឧត្តមនាយឧត្តមសេនីយ៍ **ប៉ុល សារឿន** អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ សមាជិក

១២.ឯកឧត្តមនាយឧត្តមសេនីយ៍ **សៅ សុខា** អគ្គមេបញ្ជាការរង និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

១៣.ឯកឧត្តមនាយឧត្តមសេនីយ៍ **ម៉ៅ ម៉ិនណារិន** អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុនៃក្រសួងមហាផ្ទៃ សមាជិក

១៤.អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត ជាប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត សមាជិក

**មាត្រា ២** : គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍មានភារកិច្ច ដូចតទៅ ៖

- តាមដាន ត្រួតពិនិត្យ និងគ្រប់គ្រងការប្រើប្រាស់កម្លាំងមានសមត្ថកិច្ចពាក់ព័ន្ធ ធានាឲ្យដំណើរការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតថ្នាក់ជាតិ-ថ្នាក់ក្រោមជាតិ ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩ តាមនីតិកាល និងអាណត្តិនីមួយៗ ប្រព្រឹត្តទៅប្រកបដោយសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាព គ្មានការភ័យខ្លាច ការបំភិតបំភ័យ ការគម្រាមកំហែង និងគ្មានអំពើហិង្សាផ្សេងៗ ។
- ធ្វើការពិគ្រោះយោបល់ និងចាត់ចែងផ្តល់កិច្ចសហប្រតិបត្តិការផ្នែកសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ រួមទាំងវិស័យការងារផ្សេងៗទៀតតាមសំណើរបស់ គ.ជ.ប ឬ/និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ពិសេសច្បាប់

ស្តីពីការបោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ផែនការអន្តរស្ថាប័នរបស់ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ និង គ.ជ.ប ក្រមសីលធម៌ និងសេចក្តីណែនាំផ្សេងៗទៀត ដោយឈរលើគោលការណ៍គោរពសិទ្ធិមនុស្ស នីតិរដ្ឋ និងលទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

- ធ្វើការបណ្តុះបណ្តាលកសាងសមត្ថភាព និងអប់រំផ្សព្វផ្សាយគោលការណ៍ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដល់គ្រប់យន្តការ រចនាសម្ព័ន្ធសន្តិសុខបោះឆ្នោត និងភ្នាក់ងារសន្តិសុខបោះឆ្នោតឲ្យបានជ្រួតជ្រាប និងដើម្បីសហការអនុវត្តធានាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សម្រាប់ការបោះឆ្នោតឲ្យមានលក្ខណៈកាន់តែប្រសើរឡើង ប្រកបដោយការទទួលខុសត្រូវខ្ពស់ ។
- ចាត់ចែងគ្រប់គ្រង និងប្រើប្រាស់ធនធានមនុស្ស សម្ភារ ឧបករណ៍បច្ចេកទេស និងមធ្យោបាយគ្រប់ប្រភេទរបស់ក្រសួង /ស្ថាប័ន និងអង្គភាពពាក់ព័ន្ធដែលមានស្រាប់ ក្នុងទិសដៅជម្រុញយុទ្ធនាការការពារការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតឲ្យទទួលបានជោគជ័យ ។
- លើកគម្រោងស្នើថវិកាបំប៉នដល់គ្រប់យន្តការ រចនាសម្ព័ន្ធ និងភ្នាក់ងារសន្តិសុខបោះឆ្នោត និងគម្រោងថវិកាសម្រាប់ការផ្គត់ផ្គង់ជាសម្ភារ មធ្យោបាយប្រើប្រាស់ ប្រេងឥន្ធនៈ និងការចំណាយចាំបាច់ផ្សេងៗទៀតបម្រើដល់កិច្ចប្រតិបត្តិការការពារយុទ្ធនាការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោតនីមួយៗដាក់ជូនរាជរដ្ឋាភិបាលដើម្បីពិនិត្យ និងអនុម័ត ។
- ត្រូវធ្វើរបាយការណ៍ជាប្រចាំ ជុំវិញស្ថានការណ៍សន្តិសុខបោះឆ្នោត និងអំពីសកម្មភាពប្រតិបត្តិការរបស់ភ្នាក់ងារសន្តិសុខបោះឆ្នោតជូនរាជរដ្ឋាភិបាលជ្រាប ។ ក្នុងករណីចាំបាច់ត្រូវរាយការណ៍បន្ទាន់ បំពេញភារកិច្ចផ្សេងៗតាមបញ្ញត្តិច្បាប់ជាធរមាន និងតាមការប្រគល់ជូនរបស់រាជរដ្ឋាភិបាល ។
- ជូនរាជរដ្ឋាភិបាលដើម្បីពិនិត្យ និងមានវិធានការដោះស្រាយឲ្យបានត្រឹមត្រូវ និងទាន់ពេលវេលា ។

**មាត្រា ៣ :** គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន ។

គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ត្រូវមានលេខាធិការដ្ឋានមួយ ជាសេនាធិការ នៅអគ្គស្នងការដ្ឋាននគរបាលជាតិ ដែលសមាសភាព និងតួនាទីភារកិច្ចរបស់លេខាធិការដ្ឋាននេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ ។

**មាត្រា ៤ :** គណៈអភិបាលរាជធានី ខេត្ត និងជាគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្តដែលមានស្រាប់ ត្រូវបានកំណត់ជាស្វ័យប្រវត្តិជាយន្តការ និងរចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតថ្នាក់ក្រោមជាតិ ដើម្បីគ្រប់គ្រងដឹកនាំបញ្ជា និងត្រួតពិនិត្យទៅលើការអនុវត្តរបស់ភ្នាក់ងារសន្តិសុខបោះឆ្នោត ក្នុងដែនសមត្ថកិច្ចរាជធានី ខេត្តរៀងៗខ្លួន ។ កម្លាំងនគរបាល ឬ/និងកងរាជអាវុធហត្ថ ឬ/និងកងយោធពលខេមរភូមិន្ទដែលមានមូលដ្ឋានឈរជើងនៅក្នុងទឹកដីភូមិសាស្ត្ររាជធានី ខេត្តនីមួយៗ ត្រូវរៀបចំឲ្យបំពេញភារកិច្ចជាភ្នាក់ងារសន្តិសុខបោះឆ្នោត ផ្អែកតាមផែនការដែលបានកំណត់ ។

**មាត្រា ៥ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន

និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អគ្គស្នងការនគរបាលជាតិ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ នៃក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u> ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- គ្រប់សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១២៧៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់វេទិកាសម្ព័ន្ធសង្គមស៊ីវិល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជ រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសាឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦ /០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា ១ .—**

ត្រូវបានបង្កើតវេទិកាសម្ព័ន្ធសង្គមស៊ីវិល ដែលមានអក្សរកាត់ "**វ.ស.ស.**" ដើម្បីប្រមូលផ្តុំទស្សនៈ មតិយោបល់ ពីសំណាក់ បញ្ញវន្ត ក្រុមស្រាវជ្រាវ បណ្ឌិតសភាចារ្យ សង្គមស៊ីវិល តាមរយៈកិច្ចពិភាក្សា ស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រដែលអាចលើកជាសំណើគោលនយោបាយថ្មីៗ សម្រាប់បម្រើផលប្រយោជន៍សាធារណៈ តាមគោលការណ៍ស្ម័គ្រចិត្ត ។

**មាត្រា ២ .—**

**វ.ស.ស.**មានទិសដៅ និងគោលបំណងដូចតទៅៈ

-ជាទស្សន ទូលំទូលាយសំរាប់កិច្ចពិភាក្សាលើកសំណើគោលនយោបាយថ្មីៗ
- ចងក្រងនិងរៀបចំគំនិត និងយោបល់ផ្សេងៗ និងប្រែក្លាយគំនិតយោបល់ទាំងនោះឲ្យទៅជាសំណើគោលនយោបាយមួយដែលអាចអនុវត្តបាន និងមានសុក្រឹតភាព តាមរយៈការស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ និងកិច្ចពិភាក្សាពិគ្រោះយោបល់ផ្ទៃក្នុង
- ផ្តល់ជាវេទិកាប្រកបដោយស្ថាបនាដើម្បីផ្លាស់ប្តូរមតិ យោបល់ គំនិត ជាមួយតួអង្គពាក់ព័ន្ធទាំងឡាយក្នុងដំណើរការលើកសំណើគោលនយោបាយថ្មីៗ
-សំរបសំរួល និងធ្វើសុខដុមនីយកម្មបណ្តាញនានាដើម្បីឆ្លើយតបទៅនិងបញ្ហាសំខាន់ៗក្នុងស្រុក តំបន់ និង អន្តរជាតិ

**មាត្រា ៣ .-**

**វ.ស.ស.**មានតួនាទីនិងភារកិច្ចដូចតទៅ៖

-រៀបចំវេទិកាអំពីបញ្ហានានាដែលកម្ពុជាកំពុងប្រឈម
-ប្រមូលផ្តុំមតិយោបល់ តាមវិធីសាស្ត្រស្រាវជ្រាវ និងពិភាក្សាដេញដោល ពីបញ្ញវន្ត ក្រុមស្រាវជ្រាវ បណ្ឌិតសភាចារ្យ ទាំងក្នុង និងក្រៅប្រទេស ដើម្បីចងក្រង និងបោះពុម្ពផ្សព្វផ្សាយ
- ចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលដើម្បីកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ជីវភាពប្រជាពលរដ្ឋកម្ពុជា ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល
- ចូលរួមចំណែកក្នុងការពង្រឹងនីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យ សេរីភាពបញ្ចេញមតិក្នុងក្របខ័ណ្ឌច្បាប់
- ចូលរួមចំណែកផ្សព្វផ្សាយទស្សនៈ មតិយោបល់ និងសកម្មភាពទាំងឡាយដែលមានគោលបំណងរក្សាសន្តិភាព ស្ថេរភាពនយោបាយ និងការអភិវឌ្ឍប្រកបដោយចិរភាព។
- បូកសរុបរបាយការណ៍ ទស្សនៈ និងលទ្ធផលជូនប្រមុខរាជរដ្ឋាភិបាល ។

**មាត្រា ៤ .-**

**វ.ស.ស.**មានក្រុមប្រឹក្សាភិបាលមួយដែលមានសមាសភាពតាមការចាំបាច់ ដែលត្រូវទទួលស្គាល់ដោយរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។ ក្រុមប្រឹក្សាភិបាលត្រូវដឹកនាំដោយប្រធានមួយរូប ។ សមាជិកនីមួយៗ មានតួនាទីផ្តល់យោបល់ បញ្ចេញគំនិត តាមរយៈការស្រាវជ្រាវ និងពិភាក្សាដេញដោលតាមបែបវិទ្យាសាស្ត្រដល់អគ្គលេខាធិការដ្ឋាន វ.ស.ស. ។

**មាត្រា ៥ .-**

**វ.ស.ស.**មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ ដឹកនាំដោយអគ្គលេខាធិការមួយរូប និងអមដោយអគ្គលេខាធិការរងមួយចំនួន ជាជំនួយការ។

អគ្គលេខាធិការ និងអគ្គលេខាធិការរង ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ឬអនុក្រឹត្យ។

**មាត្រា ៦ .-**

អគ្គលេខាធិការដ្ឋាន **វ.ស.ស.** មានទីស្នាក់ការនៅទីស្តីការគណៈរដ្ឋមន្ត្រី។

អគ្គលេខាធិការដ្ឋាន **វ.ស.ស.**មានមន្ត្រីក្របខណ្ឌមុខងារសាធារណៈ និងអាចជ្រើសរើសបុគ្គលិកជំនាញជាប់កិច្ចសន្យាតាមការចាំបាច់ ដើម្បីបម្រើការងារស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

**មាត្រា ៧ .-**

ប្រភពថវិការបស់ **ទ.ស.ស**.បានមកពីថវិការបស់ដៃគូរ និងសប្បុរសជនផ្សេងៗទៀត និងថវិការមួយផ្នែកតូចបានមកពីថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។ **ទ.ស.ស**.មានសិទ្ធិទទួល និងចាត់ចែងប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាននូវធនធាន និងថវិកាពីដៃគូរផ្សេងៗទៀតសម្រាប់ដំណើរការការងាររបស់ខ្លួន។

**មាត្រា ៨ .—**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៩ .—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីពាក់ព័ន្ធ និងប្រធានស្ថាប័នពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សុខ អាន**

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា៩
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧៥៩ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងលោកឧត្តមសេនីយ៍ត្រី **នៅ សុផា** អត្តលេខ ០១៣៨៣ ជាអនុប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា ១ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៦*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៦៧០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីការទូតជាន់ខ្ពស់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦ ស្តីពីការបញ្ចប់មុខងារ និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សម្រេច

**មាត្រា ១** : ត្រូវបានតែងតាំងមន្ត្រីរាជការ ចំនួន ១៣រូប របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ៖

១. លោក **ហេង ពៅ** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានអាហ្វ្រិក មជ្ឈឹមបូព៌ា ជា**អគ្គកុងស៊ុល** នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំទីក្រុងក្វាងចូវ នៃសាធារណរដ្ឋប្រជាមានិតចិន

២. លោក **គ្រុយ លឹមហេង** បច្ចុប្បន្នអធិការ នៃអគ្គាធិការដ្ឋាន ជា**អគ្គកុងស៊ុល** នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំខេត្តយូណាន ស៊ីឈុន និងហ្គីហ្សូ ដែលមាននិវេសនដ្ឋាននៅទីក្រុងគុនមិញ ខេត្តយូណាន នៃសាធារណរដ្ឋប្រជាមានិតចិន

៣. លោក **ខួន ស៊ីថត្ថា** បច្ចុប្បន្នប្រធាននាយកដ្ឋានបុគ្គលិក ជា**អគ្គកុងស៊ុល** នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំក្រុងណាននីង ខេត្តស្វយ័តក្វាងស៊ី នៃសាធារណរដ្ឋប្រជាមានិតចិន

៤. លោក **អ៊ឹម ហេន** បច្ចុប្បន្នប្រធាននាយកដ្ឋានហិរញ្ញវត្ថុ គណនេយ្យ ជា**អគ្គកុងស៊ុល** នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំទីក្រុងហូជីមិញ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម

៥. លោក **អ៊ុក តាង** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានពិធីការ ជា**ទីប្រឹក្សា** នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋប្រជាមានិតចិន

៦. លោក **ឡុង សុខន** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានសហប្រតិបត្តិការមេគង្គ ជា**ទីប្រឹក្សា** នៃស្ថានបេសកកម្មអចិន្ត្រៃយ៍កម្ពុជា ប្រចាំមន្ទីរអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិនានា នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស

៧. លោក **សេង សុជាតិ** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានអាស៊ីទី២ ជា**ទីប្រឹក្សា** នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋកូរ៉េ

៨. លោក **តាក សុវណ្ណនី** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានអឺរ៉ុប ជា**ទីប្រឹក្សា** នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំរដ្ឋគូវ៉ែត

៩. លោក **មុំ រ៉ាទីន** បច្ចុប្បន្នអនុប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានអាស៊ាន ជា**ទីប្រឹក្សា** នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំប្រទេសអូស្ត្រាលី

១០. លោក **ហាស់ សំបូរ** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានរដ្ឋបាល ជា**ទីប្រឹក្សា** នៃស្ថានបេសកកម្មអចិន្ត្រៃយ៍កម្ពុជា ប្រចាំអង្គការសហប្រជាជាតិ នៅទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក

១១. លោក **គីម សុវណ្ណា** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានច្បាប់ និងកុងស៊ុល ជា**ទីប្រឹក្សា** នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសហរដ្ឋអាមេរិក

១២. លោក **គៀត សន្តារ៉ាវី** បច្ចុប្បន្នប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ជា**ទីប្រឹក្សា** នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

១៣. លោក **ហូ ពេជ្រមោលី** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានច្បាប់ និងកុងស៊ុល ជា**ទីប្រឹក្សា** នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋអារ៉ាប់អេហ្ស៊ីប។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល:</u>
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៦៦១ អនក្រ.បក

# អនុក្រឹត្យ

**ស្តីពី**

**ការបញ្ចប់អាណត្តិបេសកកម្មមន្ត្រីការទូតជាន់ខ្ពស់**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦ ស្តីពីការបញ្ចប់មុខងារ និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

**សម្រេច**

**មាត្រា ១** : ត្រូវបានផ្លាស់មន្ត្រីរាជការ ចំនួន ០៩រូប ចូលប្រទេស ដោយត្រូវចប់អាណត្តិបេសកកម្មៈ

១. លោក **ហួ សុផារ៉ា** បច្ចុប្បន្ន**អគ្គកុងស៊ុល** នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំទីក្រុងក្វាងចូវ នៃសាធារណរដ្ឋប្រជាមានិតចិន

២. លោក **សៅ ខូវ៉ាឌីន** បច្ចុប្បន្ន**អគ្គកុងស៊ុល** នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំខេត្តយូណាន ស៊ីឈុន និងហ្គីហ្សូ ដែលមាននិវេសនដ្ឋាននៅទីក្រុងគុនមិញ ខេត្តយូណាន នៃសាធារណរដ្ឋប្រជាមានិតចិន

៣. លោក **អ៊ឹម សុធីរ** បច្ចុប្បន្ន**អគ្គកុងស៊ុល** នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំទីក្រុងណាននីង ខេត្តស្វយ័តក្វាងស៊ី នៃសាធារណរដ្ឋប្រជាមានិតចិន

៤. លោក **ស៊ឹម សុខុម** បច្ចុប្បន្ន**អគ្គកុងស៊ុល** នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំទីក្រុងហូជីមិញ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម

៥. លោក **នួន ជីវន្ត** បច្ចុប្បន្ន**អគ្គទីប្រឹក្សា** នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋប្រជាមានិតចិន

៦. លោក **អ៊ុច ហ៊ាង** បច្ចុប្បន្ន**អគ្គទីប្រឹក្សា** នៃស្ថានបេសកកម្មអចិន្ត្រៃយ៍កម្ពុជា ប្រចាំមន្ទីរអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិនានា នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស

៧. លោកស្រី **អ៊ុង មុទផល** បច្ចុប្បន្ន**ទីប្រឹក្សា** នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋកូរ៉េ

៨. លោក **ឆាម សុធី** បច្ចុប្បន្ន**ទីប្រឹក្សា** នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំរដ្ឋគុវ៉ែត

៩. លោក **ម៉ិច សុផាត** បច្ចុប្បន្ន**អគ្គទីប្រឹក្សា** នៃស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំសាធារណរដ្ឋបារាំង។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល៖</u>
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៦៦៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

**សម្រេច**

**មាត្រា ១.-** បំពាក់ មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ ចំនួន ១២ គ្រឿង ជូនសប្បុរសជន ១២ រូប ដែលបានខិតខំបំពេញការងារ និងសហការល្អ ដូចមានរាយនាមខាងក្រោម៖

| | | | |
|---|---|---|---|
| ១- | Mrs. | Sunee Satjachaiyanon | សប្បុរសជន នៅព្រះរាជាណាចក្រថៃ |
| ២- | Mrs. | Warapon Lao | សប្បុរសជន នៅព្រះរាជាណាចក្រថៃ |
| ៣- | Mrs. | Pacharawan Chandrangsu | សប្បុរសជន នៅព្រះរាជាណាចក្រថៃ |
| ៤- | Mrs. | Chatnitha Sornwaeo | សប្បុរសជន នៅព្រះរាជាណាចក្រថៃ |
| ៥- | Mrs. | Kea ara Taranop | សប្បុរសជន នៅព្រះរាជាណាចក្រថៃ |
| ៦- | Mrs. | Supathip Thipwattan | សប្បុរសជន នៅព្រះរាជាណាចក្រថៃ |
| ៧- | Miss | Thanveerint Pornchai Thanabaudee | សប្បុរសជន នៅព្រះរាជាណាចក្រថៃ |
| ៨- | Dr. | Wanpen Pongkao | សប្បុរសជន នៅព្រះរាជាណាចក្រថៃ |
| ៩- | Dr. | Yirikan OnsonKarn | សប្បុរសជន នៅព្រះរាជាណាចក្រថៃ |
| ១០- | Mrs. | Yaowanrn Vatkarn | សប្បុរសជន នៅព្រះរាជាណាចក្រថៃ |

| | | | |
|---|---|---|---|
| ១១- | Mrs. | Monnaphak Theetrakool | សប្បុរសជន នៅព្រះរាជាណាចក្រថៃ |
| ១២ | Mrs. | Wanee Wathcharatangka | សប្បុរសជន នៅព្រះរាជាណាចក្រថៃ |

**មាត្រា ២.-**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៦*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល:</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ៦៦៣ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១:** តម្លើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូននាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៖

| | | | | |
|---|---|---|---|---|
| ១- | វរសេនីយ៍ទោ | **ម៉ៅ** | **សាម៉េត** | អត្តលេខ ០១៧៩៧ |
| ២- | វរសេនីយ៍ទោ | **ខៀវ** | **ស៊ីណារួត** | អត្តលេខ ០៣១៩៩ |
| ៣- | វរសេនីយ៍ទោ | **ថាច់** | **សខ** | អត្តលេខ ០១១៨៤ |
| ៤- | វរសេនីយ៍ទោ | **ឡូន** | **វិបុល** | អត្តលេខ ០១៨៨៥ |
| ៥- | វរសេនីយ៍ទោ | **លី** | **តៃឈុន** | អត្តលេខ ០២៧៨២ |
| ៦- | វរសេនីយ៍ទោ | **គឹម** | **សារឿន** | អត្តលេខ ០២៨៦៦ |
| ៧- | វរសេនីយ៍ទោ | **អន** | **ឌា** | អត្តលេខ ០២៨៩៣ |
| ៨- | វរសេនីយ៍ទោ | **ឈុន** | **ចន្ទតារា** | អត្តលេខ ០២៩១៨ |
| ៩- | វរសេនីយ៍ទោ | **សាយ** | **សាមុធ** | អត្តលេខ ០២៩៩០ |
| ១០- | វរសេនីយ៍ទោ | **សន** | **មុនី** | អត្តលេខ ០២៩៩០ |
| ១១- | វរសេនីយ៍ទោ | **ជិន** | **សុផាត** | អត្តលេខ ០៣០៤២ |

១២- វរសេនីយ៍ទោ **ឃីម សុមន្ដា** អត្តលេខ ០៣១៥៤
១៣- វរសេនីយ៍ទោ **ប៉ាក់ សុខា** អត្តលេខ ០៣១៨០
១៤- វរសេនីយ៍ទោ **ផែង សារិទ្ធ** អត្តលេខ ០៣១៨៩
១៥- វរសេនីយ៍ទោ **ជា ពឿន** អត្តលេខ ០៣៣២៩
១៦- វរសេនីយ៍ទោ **នេត សារឿន** អត្តលេខ ០៣៣៩៦
១៧- វរសេនីយ៍ទោ **រុំ សុចិន្ដា** អត្តលេខ ០៣៨៧៤
១៨- វរសេនីយ៍ទោ **ស៊ិន ណារ៉ាក់** អត្តលេខ ០៤២៥៦
១៩- វរសេនីយ៍ទោ **ជូ ចិត្ត** អត្តលេខ ០៤៣១៥
២០- វរសេនីយ៍ទោ **សែម សុជាតិ** អត្តលេខ ០៤៦០៨
២១- វរសេនីយ៍ទោ **កែវ ឆា** អត្តលេខ ០៤៧៩០
២២- វរសេនីយ៍ទោ **នៅ សាវុធ** អត្តលេខ ០៧៣៩៨
២៣- វរសេនីយ៍ទោ **ស៊ឹង សុភក្រ័** អត្តលេខ ០៨១៦៨
២៤- វរសេនីយ៍ទោ **ខួយ កុសល** អត្តលេខ ០៨១៧០
២៥- វរសេនីយ៍ទោ **គីម សុខ** អត្តលេខ ០៨៣៣៨
២៦- វរសេនីយ៍ទោ **ស សាលី** អត្តលេខ ០៨៧៩៨
២៧- វរសេនីយ៍ទោ **ស៊ូ សុខមា** អត្តលេខ ០៨៨២០
២៨- វរសេនីយ៍ទោ **ឡឹក មីផែល** អត្តលេខ ០៩០១៦
២៩- វរសេនីយ៍ទោ **យ៉ុន នី** អត្តលេខ ០៩៤៣០
៣០- វរសេនីយ៍ទោ **លឹម ម៉ូរ៉ាន់** អត្តលេខ ១១៤៨៩
៣១- វរសេនីយ៍ទោ **ប៉េង ពិសិដ្ឋ** អត្តលេខ ១៤៤៣៦
៣២- វរសេនីយ៍ទោ **ព្រំ ពិសិដ្ឋ** អត្តលេខ ១៥៦៧០
៣៣- វរសេនីយ៍ទោ **ម៉ូ សារ៉េន** អត្តលេខ ១៥៦៧០
៣៤- វរសេនីយ៍ទោ **នៅ សុផល** អត្តលេខ ១៦០០៧
៣៥- វរសេនីយ៍ទោ **សឿម សារិទ្ធ** អត្តលេខ ២២១៥៣
៣៦- វរសេនីយ៍ទោ **សុក សំបូរ** អត្តលេខ ៣៣៥៥៦ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា ១ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ.ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៦*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៧៦៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយសុវត្ថារា
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១.**_បំពាក់មេដាយសុវត្ថារា ថ្នាក់ **ធិបឌិន្ទ** ជូនជំនាញការជប៉ុន ចំនួន០៦រូប ដែលមានស្នាដៃល្អក្នុងការចូលរួមជួយការងារគម្រោងការពារទឹកជំនន់ កែលម្អប្រព័ន្ធប្រឡាយ លូ និងគម្រោងកែលម្អប្រព័ន្ធចរាចរណ៍ នៅរាជធានីភ្នំពេញ ដូចមានរាយនាមខាងក្រោម ៖

| | | |
|---|---|---|
| ១-Mr. | TOGO UCHIDA | Project Formulation Advisor/JICA |
| ២-Mr. | KEIJI SASABE | President of CTIi |
| ៣-Mr. | TSUYOSHI MATSUSHITA | Project Manager , CTIi Consultant |
| ៤-Mr. | TAKUJI SHIGEYAMA | Project Manager , SMCC Contractor |
| ៥-Mr. | HIDEO MEADA | Resident Representative of CTIi |
| ៦-Mr. | MASATO KOTO | Chief Consultant /METS |

**មាត្រា២.**_រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៦
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:..៧៦៥..អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១.** បំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេននិងជូនសប្បុរសជន ចំនួន១៣រូប ដែលបានបរិច្ចាគធនធានចូលរួមជួយកសាងសមិទ្ធផលនានា ក្នុងវិស័យព្រះពុទ្ធសាសនា នៅវត្តតាំងកសាងខាងជើង សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កន្លងមក ដូចមានរាយព្រះនាមនិងនាមខាងក្រោម ៖

| | | |
|---|---|---|
| ១-ព្រះតេជគុណ | **សែម សុភា** | ព្រះវិន័យធរអនុគណខណ្ឌពោធិ៍សែនជ័យ |
| ២-ឯកឧត្តម | **គ្រួច ផាន** | ប្រធានក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យ |
| ៣-លោក | **ហែម ជារិទ្ធិ** | អភិបាលនៃគណៈអភិបាលខណ្ឌពោធិ៍សែនជ័យ |
| ៤-លោក | **ខៀវ ឃីនាថ** | សមាជិកក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យ |
| ៥-លោក | **លឹម រដ្ឋា** | សមាជិកក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យ |
| ៦-លោក | **យិន គា** | នាយករដ្ឋបាល សាលាខណ្ឌពោធិ៍សែនជ័យ |
| ៧-លោក | **សំ ឆា** | ប្រធានការិយាល័យអន្តរវិស័យសាលាខណ្ឌពោធិ៍សែនជ័យ |
| ៨-លោក | **យុគ សារ៉ាត់** | សប្បុរសជននៅរាជធានីភ្នំពេញ |
| ៩-លោក | **សុខ អ៊ែល** | ចៅសង្កាត់កាកាប |
| ១០-ព្រះតេជគុណ | **គីម ឆួង** | ព្រះចៅអធិការវត្តតាំងកសាងខាងជើង |
| ១១-ព្រះតេជគុណ | **អឿន ជិន** | គង់នៅរាជធានីភ្នំពេញ |
| ១២-លោក | **ឃិត ឈឿន** | សប្បុរសជននៅរាជធានីភ្នំពេញ |
| ១៣-លោក | **ជៀក គីមឡុង** | សប្បុរសជននៅរាជធានីភ្នំពេញ |

| | | | |
|---|---|---|---|
| ១៤-ព្រះតេជគុណ | ទូច | ម៉ៃ | ព្រះគ្រូសូត្រស្ដាំវត្តមហាមន្ត្រី |
| ១៥-ព្រះតេជគុណ | ថា | ប៊ុនឡាត់ | គង់នៅរាជធានីភ្នំពេញ |
| ១៦-ព្រះតេជគុណ | ម៉ក់ | សុខន | គង់នៅរាជធានីភ្នំពេញ |
| ១៧-ព្រះតេជគុណ | ខៀវ | សំអាង | គង់នៅរាជធានីភ្នំពេញ |
| ១៨-លោក | សៅ | សុធា | សប្បុរសជននៅរាជធានីភ្នំពេញ |
| ១៩-លោក | កែវ | សុតា | សប្បុរសជននៅរាជធានីភ្នំពេញ |
| ២០-អ្នកស្រី | អ៊ុំ | ថាវី | សប្បុរសជននៅរាជធានីភ្នំពេញ |
| ២១-សម្ដេចព្រះមហាអរិយវង្ស | សៅរ៍ | ចន្ទថុល្ល | ព្រះបាឡាត់គណរាជធានីភ្នំពេញ |
| ២២-ព្រះតេជគុណ | សឿ | ហេង | គង់នៅរាជធានីភ្នំពេញ |
| ២៣-ព្រះតេជគុណ | អ៊ុង | ពិសី | គង់នៅរាជធានីភ្នំពេញ |
| ២៤-ព្រះតេជគុណ | គង់ | សុឃាន | គង់នៅរាជធានីភ្នំពេញ |
| ២៥-លោក | ឆាម | សេងហ៊ួរ | សប្បុរសជននៅរាជធានីភ្នំពេញ |
| ២៦-លោក | សុខ | វី | សប្បុរសជននៅរាជធានីភ្នំពេញ |
| ២៧-លោក | មាស | គា | សប្បុរសជននៅរាជធានីភ្នំពេញ |
| ២៨-លោក | ចាន់ | សេម | សប្បុរសជននៅរាជធានីភ្នំពេញ |
| ២៩-លោក | យ៉េម | វណ្ណៈ | សប្បុរសជននៅរាជធានីភ្នំពេញ |
| ៣០-លោក | ជុំ | បូរ | សប្បុរសជននៅរាជធានីភ្នំពេញ |
| ៣១-លោក | ឈុប | សុវណ្ណ | សប្បុរសជននៅរាជធានីភ្នំពេញ |
| ៣២-លោក | ស្រៀង | វុទ្ធី | សប្បុរសជននៅរាជធានីភ្នំពេញ |
| ៣៣-លោក | ប៊ុន | នាថ | សប្បុរសជននៅរាជធានីភ្នំពេញ |
| ៣៤-លោក | យ៉ក | ម៉ិញហ៊ុច | សប្បុរសជននៅរាជធានីភ្នំពេញ |
| ៣៥-លោក | ផាត | ស៊ីនអ៊ុង | សប្បុរសជននៅរាជធានីភ្នំពេញ |
| ៣៦-លោក | សុខ | ឡឿន | សប្បុរសជននៅរាជធានីភ្នំពេញ |
| ៣៧-អ្នកស្រី | ស៊ីន | អាន | សប្បុរសជននៅរាជធានីភ្នំពេញ |
| ៣៨-លោក | អាង | សំអាត | សប្បុរសជននៅរាជធានីភ្នំពេញ |

**មាត្រា២.** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។៚

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៦

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៦៦៦ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សម្រេច

**មាត្រា ១** : តែងតាំងលោក **ខណ្ណ តារា** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៦*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យសម្តេច ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី*
*-ដូចមាត្រា៣*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៩៧ អនក្រ.បក

## អនុក្រឹត្យ

### ស្តីពី

### ការតែងតាំងមុខតំណែង និងតម្លើងឋានន្តរស័ក្តិ មន្ត្រីនគរបាលជាតិកម្ពុជា

### រាជរដ្ឋាភិបាល

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការ រៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា ១** : តែងតាំងមុខតំណែងជូននាយនគរបាលជាន់ខ្ពស់ ចំនួន ០៣រូប ជាសមាជិកក្រុមប្រឹក្សានីតិកម្ម មានឋានៈស្មើប្រធាននាយកដ្ឋាន នៃក្រសួងមហាផ្ទៃ ៖

១-លោកឧត្តមសេនីយ៍ឯក **ស៊ុន ហួរ** អត្តលេខ ៧៨១១១

២-លោកឧត្តមសេនីយ៍ត្រី **ចាន់ សុខា** អត្តលេខ ២១៨៦៣

៣-លោកវរសេនីយ៍ទោ **អ៊ឹម ថានី** អត្តលេខ ០៩៨៦៣ ។

**មាត្រា ២**: ដំឡើងឋានន្តរស័ក្តិ **វរសេនីយ៍ឯក** ជូននាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៖

១- លោកវរសេនីយ៍ទោ **អ៊ឹម ថានី** អត្តលេខ ០៩៨៦៣

២-លោកវរសេនីយ៍ទោ **ខែម សាម៉េន** អត្តលេខ ៣២៥៣៦

៣-លោកវរសេនីយ៍ទោ **សៀ ម៉ាប់** អត្តលេខ ៥៧៤៥៧ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ និងមាត្រា២ ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០១៦*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៦៦៧ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពីការផ្ទេរសម្រួលភារកិច្ចមន្ត្រីរាជការ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យ លេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យ លេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ ស្ដីពីការកំណត់រចនាសម្ព័ន្ធ គ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១:** ផ្ទេរសម្រួលភារកិច្ចលោក **ស្រី សុធា** ពីអគ្គលេខាធិការរង ទៅជាអគ្គាធិការរង នៃអគ្គាធិការដ្ឋាន នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល ÷
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ  សាសនា  ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៦៧៩ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៤៨៤ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការការងារចាំបាច់

**សម្រេច**

**មាត្រា ១** : តែងតាំងលោក **ឆាយ សុខហេង** ជាជំនួយការសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ អគ្គនាយករង ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី គ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែមិថុនា ឆ្នាំ ២០១៦*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៥៧ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីសម្របសម្រួលរៀបចំខ្លឹមសារសម្រាប់កិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃលើកទី៦

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីសម្របសម្រួលរៀបចំខ្លឹមសារសម្រាប់កិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃលើកទី៦ ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១- ឯកឧត្តម **សក់ សេដ្ឋា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ជាប្រធាន |
| ២- រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៣- រដ្ឋលេខាធិការក្រសួងការពារជាតិ | អនុប្រធាន |

| | |
|---|---|
| ៤- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ជាសមាជិក |
| ៥- តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ជាសមាជិក |
| ៦- តំណាងគណៈកម្មាធិការជាតិទទួលបន្ទុកកិច្ចការព្រំដែន | ជាសមាជិក |
| ៧- តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន | ជាសមាជិក |
| ៨- តំណាងក្រសួងពាណិជ្ជកម្ម | ជាសមាជិក |
| ៩- តំណាងក្រសួងទេសចរណ៍ | ជាសមាជិក |
| ១០- តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ជាសមាជិក |
| ១១- តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ជាសមាជិក |
| ១២- តំណាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន | ជាសមាជិក |
| ១៣- អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ | ជាសមាជិក |
| ១៤- អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ | ជាសមាជិក |
| ១៥- អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ | ជាសមាជិក |
| ១៦- អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ | ជាសមាជិក |
| ១៧- អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ | ជាសមាជិក |

**ប្រការ ២.-**

គណៈកម្មការខាងលើនេះ មានតួនាទី ភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាលកម្ពុជា និងបណ្តាខេត្តកម្ពុជា ដែលជាប់ព្រំដែនជាមួយប្រទេសថៃ ដើម្បីត្រៀមរៀបចំខ្លឹមសារនានាសម្រាប់កិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃលើកទី៦
- ពិភាក្សា និងសម្របសម្រួលជាមួយភាគីថៃ ក្នុងការរៀបចំខ្លឹមសារកិច្ចប្រជុំឱ្យបានសមស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា និងកិច្ចការផ្សេងៗទៀតដែលបម្រើឱ្យកិច្ចប្រជុំ
- ក្នុងការត្រៀមរៀបចំខ្លឹមសារខាងលើនេះ ប្រធានគណៈកម្មការត្រូវរាយការណ៍សុំយោបល់ដឹកនាំជាប្រចាំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- គណៈកម្មការមានសិទ្ធិកោះអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធចូលរួមប្រជុំពិភាក្សាការងារសម្រាប់រៀបចំកិច្ចប្រជុំនេះ តាមការចាំបាច់
- ប្រធានគណៈកម្មការមានសិទ្ធិស្នើសុំរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីបង្កើតក្រុមការងារសម្រាប់គាំទ្រដល់កិច្ចប្រជុំនេះតាមការចាំបាច់
- អនុប្រធាន និងសមាជិកគណៈកម្មការត្រូវចូលរួមកិច្ចប្រជុំ និងទទួលភារកិច្ចនានាតាមការចាត់ចែងរបស់ប្រធានគណៈកម្មការ។

**ប្រការ ៣.-**

គណៈកម្មការមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ ដើម្បីចាត់ចែងការងាររបស់ខ្លួន និងប្រើប្រាស់ថវិការបស់ក្រសួងមហាផ្ទៃ ដើម្បីចាត់ចែងការងាររបស់គណៈកម្មការ និងសម្រាប់រៀបចំកិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃលើកទី៦នេះ។

**ប្រការ ៤.-**

គណៈកម្មការត្រូវបញ្ចប់ការងាររបស់ខ្លួន បន្ទាប់ពីកិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃលើកទី៦ ត្រូវបានបញ្ចប់រួចរាល់ជាស្ថាពរ និងបានធ្វើសេចក្ដីរាយការណ៍អំពីលទ្ធផលនៃកិច្ចប្រជុំជូនប្រមុខរាជរដ្ឋាភិបាល និង ក្រសួង ស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាលកម្ពុជា។

**ប្រការ ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និងឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ដែលមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៦០. សសរ

**សេចក្តីសម្រេច**
**ស្តីពី**
**ការបង្កើតគណៈកម្មាធិការសម្របសម្រួលអន្តរក្រសួង**
**គ្រប់គ្រង និងត្រួតពិនិត្យទំនិញគ្រោះថ្នាក់**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៣ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីស្តង់ដារកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

**សម្រេច**

**ប្រការ១._**

បង្កើតគណៈកម្មាធិការសម្របសម្រួលអន្តរក្រសួងគ្រប់គ្រង និងត្រួតពិនិត្យទំនិញគ្រោះថ្នាក់ ដើម្បីធានាបាននូវការសម្របសម្រួលក្នុងក្របខណ្ឌថ្នាក់ជាតិ ដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យ ការផលិត ការប្រើប្រាស់

ការនាំចូល ការនាំចេញ ការដឹកជញ្ជូន និងការស្តុកទុកទំនិញគ្រោះថ្នាក់ ដែលអាចបង្កមហន្តរាយដល់ មនុស្ស សត្វ បរិស្ថាន និងសន្តិសុខសង្គម។

**ប្រការ២._**

គណៈកម្មាធិការសម្របសម្រួលអន្តរក្រសួងនេះ មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១. រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម | ប្រធាន |
| ២. តំណាងក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣. តំណាងក្រសួងការពារជាតិ | អនុប្រធាន |
| ៤. តំណាងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | អនុប្រធាន |
| ៥. តំណាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម | អនុប្រធានអចិន្ត្រៃយ៍ |
| ៦. តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៧. តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៨. តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៩. តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១០. តំណាងក្រសួងសុខាភិបាល | សមាជិក |
| ១១.តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១២. តំណាងក្រសួងបរិស្ថាន | សមាជិក |
| ១៣. តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១៤. តំណាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន | សមាជិក |
| ១៥. តំណាងអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិអាវុធគីមី អាវុធនុយក្លេអែរ អាវុធជីវសាស្ត្រ និងអាវុធវិទ្យុសកម្ម | សមាជិក |
| ១៦. តំណាងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | សមាជិក |
| ១៧. តំណាងកំពង់ផែស្វយ័តព្រះសីហនុ | សមាជិក |
| ១៨. តំណាងកំពង់ផែស្វយ័តភ្នំពេញ | សមាជិក |

**ប្រការ៣._**

គណៈកម្មាធិការនេះមានតួនាទី និងភារកិច្ច ដូចតទៅ៖

- បំពេញការងារជាសេនាធិការជូនថ្នាក់ដឹកនាំក្រសួង/ស្ថាប័នពាក់ព័ន្ធ ក្នុងការសិក្សាពីកាតព្វកិច្ច និងតម្រូវការរបស់ជាតិលើការចូលរួមគ្រប់គ្រង និងត្រួតពិនិត្យទំនិញគ្រោះថ្នាក់ សម្រាប់ជាមូលដ្ឋាន នៃការធ្វើសេចក្តីសម្រេចចិត្ត និងជំរុញការចូលរួមអនុវត្តន៍ឲ្យមានប្រសិទ្ធភាពខ្ពស់
- រៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រជាតិលើការគ្រប់គ្រងទំនិញគ្រោះថ្នាក់ឲ្យទទួលបាននូវសុវត្ថិភាព ជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច
- រៀបចំគ្រប់គ្រង និងបង្កើតប្រព័ន្ធទិន្នន័យជាតិ ស្តីពីទំនិញគ្រោះថ្នាក់
- ប្រមូលគ្រប់ព័ត៌មានដែលទាក់ទងនឹងទំនិញគ្រោះថ្នាក់ ព្រមទាំងធ្វើការពិនិត្យ វិភាគ និងវាយតម្លៃទិន្នន័យ នៃភាពមិនប្រក្រតីក្នុងការផលិត ការប្រើប្រាស់ ការដឹកជញ្ជូន ការនាំចូល ការនាំចេញ និងការស្តុកទុក

ទំនិញគ្រោះថ្នាក់ ដែលពាក់ព័ន្ធនឹងក្រសួង/ស្ថាប័នរបស់ខ្លួន ហើយរាយការណ៍ជាប្រចាំតាមរបៀបរបបការងារដែលប្រធានបានកំណត់

- ផ្លាស់ប្តូរ និងផ្តល់ព័ត៌មានជាប្រចាំរវាងក្រសួង/ស្ថាប័នពាក់ព័ន្ធ ពិសេសព័ត៌មានដែលទាក់ទងដល់ការផលិត ការប្រើប្រាស់ ការដឹកជញ្ជូន និងការស្តុកទុកទំនិញគ្រោះថ្នាក់
- ចូលរួមផ្តល់យោបល់លើសេចក្តីព្រាងលិខិតបទដ្ឋាន ច្បាប់ និងផែនការសកម្មភាពជាតិ ដែលទាក់ទងទៅនឹងការគ្រប់គ្រង និងការត្រួតពិនិត្យទំនិញគ្រោះថ្នាក់
- សិក្សា និងវាយតម្លៃពីបញ្ហាប្រឈម និងពីចំណុចខ្វះខាតលើការគ្រប់គ្រង និងការត្រួតពិនិត្យទំនិញគ្រោះថ្នាក់ នៅក្នុងក្របខណ្ឌជាតិ និងរាយការណ៍ជូនថ្នាក់ដឹកនាំក្រសួង/ស្ថាប័នពាក់ព័ន្ធជ្រាប ពីតម្រូវការចាំបាច់បន្ថែមសម្រាប់ឈានទៅគ្រប់គ្រង និងត្រួតពិនិត្យទំនិញគ្រោះថ្នាក់ប្រកបដោយសុវត្ថិភាព
- រៀបចំ និងប្រមូលយកព័ត៌មានពាក់ព័ន្ធទៅនឹងបញ្ហាគ្រប់គ្រង និងត្រួតពិនិត្យទំនិញគ្រោះថ្នាក់ក្នុងក្របខណ្ឌជាតិ និងអន្តរជាតិ ដើម្បីរាយការណ៍ជូនថ្នាក់ដឹកនាំតាមក្រសួង/ស្ថាប័នពាក់ព័ន្ធជ្រាប និងដើម្បីមានវិធានការសមស្របក្នុងករណីចាំបាច់ និងទាន់ពេលវេលា
- ជួយសម្របសម្រួលដល់ការងារទំនាក់ទំនងរវាងក្រសួង/ស្ថាប័នពាក់ព័ន្ធ និងផ្លាស់ប្តូរព័ត៌មានក្នុងចំណោមសមាជិកក្រុមការងារលើរាល់បញ្ហាទាក់ទងទៅនឹងការគ្រប់គ្រង និងត្រួតពិនិត្យ ទំនិញគ្រោះថ្នាក់
- សម្របសម្រួលដល់បណ្តាគម្រោង កម្មវិធី និងសកម្មភាពស្រាវជ្រាវនានាក្នុងក្របខណ្ឌជាតិ ដែលពាក់ព័ន្ធនឹងការចូលរួមអនុវត្តអនុសញ្ញា សន្ធិសញ្ញា ពិធីសារ និងកិច្ចព្រមព្រៀងអន្តរជាតិនានា ដែលទាក់ទងទៅនឹងការគ្រប់គ្រង និងត្រួតពិនិត្យទំនិញគ្រោះថ្នាក់
- លើកឡើងនូវវិធានការចាំបាច់នានា ដើម្បីធានាដល់ការគ្រប់គ្រង និងត្រួតពិនិត្យការផលិត ការប្រើប្រាស់ ការដឹកជញ្ជូន និងការស្តុកទុកទំនិញគ្រោះថ្នាក់
- ផ្តល់ប្រឹក្សាយោបល់ទៅក្រសួង/ស្ថាប័នពាក់ព័ន្ធ ដើម្បីចាត់វិធានការធានាបង្ការគ្រោះថ្នាក់។

**ប្រការ៤._**

ឈ្មោះសមាជិកគណៈកម្មាធិការសម្របសម្រួលអន្តរក្រសួងគ្រប់គ្រង និងត្រួតពិនិត្យទំនិញគ្រោះថ្នាក់ ដូចមានចែងក្នុងមាត្រា ២ ខាងលើ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

សមាជិកនីមួយៗ ត្រូវអនុវត្តតាមភារកិច្ចដែលមានចែងក្នុងមាត្រា ៣ ខាងលើ និងត្រូវចូលរួមប្រជុំឲ្យបានទៀងទាត់តាមការកោះអញ្ជើញរបស់ប្រធាន។ ពេលប្រធានអវត្តមាន គណៈកម្មាធិការសម្របសម្រួលអន្តរក្រសួងអាចប្រជុំក្រោមការដឹកនាំរបស់អនុប្រធានតាមការប្រគល់សិទ្ធិពីប្រធាន។

**ប្រការ៥._**

គណៈកម្មាធិការសម្របសម្រួលអន្តរក្រសួង គ្រប់គ្រង និងត្រួតពិនិត្យទំនិញគ្រោះថ្នាក់ មានលេខាធិការដ្ឋាននៅវិទ្យាស្ថានស្តង់ដារកម្ពុជា នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៦._**

គណៈកម្មាធិការសម្របសម្រួលអន្តរក្រសួង ត្រួតពិនិត្យទំនិញគ្រោះថ្នាក់ មានសិទ្ធិបង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួងមួយចំនួន ដោយចាត់តាំងមន្ត្រីក្រោមឱវាទក្រសួង/ស្ថាប័នពាក់ព័ន្ធជាសមាជិក ដើម្បីជួយការងារតាមការចាំបាច់។

**ប្រការ៧.**_

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៨.**_

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងបរិស្ថាន អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន អនុប្រធានប្រចាំការនៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**

**__កន្លែងទទួល៖__**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៦១ សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការតែងតាំងទីប្រឹក្សាសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៤៨៤ អនក្រ.បក ចុះថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១** : តែងតាំងលោក **តាមី ពៀរចចូ ម៉ារៀ** (Tami Piergiorgio Maria) (ឈ្មោះខ្មែរ **សែន សីលា**) ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

***Kingdom of Cambodia***

រាជរដ្ឋាភិបាល

***Royal Government***

ជាតិ សាសនា ព្រះមហាក្សត្រ

***Nation Religion King***

N°: ...61...DC

# DECISION
# ON
# THE NOMINATION OF ADVISER TO SAMDECH AKKA MOHA SENA PADEI TECHO HUN SEN, PRIME MINISTER OF THE KINGDOM OF CAMBODIA

## ROYAL GOVERNMENT OF CAMBODIA

- Having seen the Constitution of the Kingdom of Cambodia
- Having seen Preah Reach Kret No. NS/RKT/0913/903 dated 24 September 2013 on the appointment of the Royal Government of Cambodia
- Having seen Preah Reach Kram No. 02/NS/94 dated 20 July 1994 Promulgating on the Law on the Organisation and Functioning of the Council of the Ministers
- Having seen Sub-Decree No. 484 ANK.BK dated 26 September 2013 on the Establishment of the Cabinet of Samdech Akka Moha Sena Padei Techo HUN SEN, Prime Minister of the Kingdom of Cambodia
- Pursuant to the need of the Royal Government

## DECIDES

**Article 1:** To appoint Mr. **Tami Piergiorgio Maria** (name in Khmer **Sen Seila**) as Personal Adviser to Samdech Akka Moha Sena Padei Techo HUN SEN, Prime Minister of the Kingdom of Cambodia.

**Article 2:** The Minister of the Council of Ministers, Minister of Economy and Finance, Minister of Public Function, all relevant Ministers/Institutions and person as described in Article 1 to implement this decision effectively from the date of signature herein.

Phnom Penh, June 24, 2016

**Prime Minister**

**Samdech Akka Moha Sena Padei Techo HUN SEN**

CC:

- Cabinet of the Royal Palace
- General Secretariat of the Constitutional Council
- General Secretariat of the Senate
- General Secretariat of the National Assembly
- General Secretary of the Royal Government
- Cabinet of the Prime Minister
- Cabinet of the Deputy Prime Minister
- as Article 2
- Office Journal-Archives

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ.៣៣៧......សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦

## ប្រកាស
## ស្តីពី
## បែបបទ និងនីតិវិធីចំណាយលើការជួសជុលអន្តរាគមន៍ជួសជុលបន្ទាន់ផ្លូវជនបទ ស្ពាន និងលូ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការត្រួតពិនិត្យហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- យោងតាមតម្រូវការចាំបាច់ការងារ

## សម្រេច

**ប្រការ១:** ត្រូវបានបម្រុងឥណទានថវិកាមិនលើសពីចំនួន ២០% (ម្ភៃភាគរយ) នៃឥណទានថវិកាជំពូក៦១ (ការងារជួសជុលនិងថែទាំផ្លូវជនបទ) នៃកញ្ចប់ថវិកាក្រសួងអភិវឌ្ឍន៍ជនបទប្រចាំឆ្នាំ សម្រាប់ត្រៀមប្រើប្រាស់អន្តរាគមន៍ជួសជុលបន្ទាន់ផ្លូវជនបទ ស្ពាន និងលូទាំងឡាយណាដែលកំពុងដំណើរការ ហើយត្រូវបានខូចខាត/កាត់ផ្តាច់ ឬ រកកល់នឹងខូចខាត/កាត់ផ្តាច់ ដោយប្រការណាមួយ។

**ប្រការ២:** ថវិកានេះនឹងត្រូវផ្តល់ជូនអង្គភាពជំនាញក្រោមឱវាទក្រសួងអភិវឌ្ឍន៍ជនបទ តាមរបៀបដូចខាងក្រោម÷

- នៅរៀងរាល់ដើមឆ្នាំ ក្រោយពីទទួលបានសំណើរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ថវិកាចំនួន ៥០% (ហាសិបភាគរយ) នៃកញ្ចប់ថវិកាអន្តរាគមន៍ជួសជុលបន្ទាន់ នឹងត្រូវផ្តល់ជូនមុនតាមរយៈបុរេប្រទាន។
- ការបើកផ្តល់បន្ទាប់មកទៀត នឹងត្រូវធ្វើឡើងក្រោមរូបភាពជាការបំពេញឡើងវិញនូវថវិកាដែលបានចំណាយ រហូតដល់អស់កញ្ចប់ឥណទានថវិកាបម្រុងប្រចាំឆ្នាំ។
- ដើម្បីសម្រួលដល់ការបំពេញថវិកាឡើងវិញឱ្យមានប្រសិទ្ធិភាពខ្ពស់ របាយការណ៍ចំណាយនិងរបាយការណ៍អនុវត្តការងារ ត្រូវផ្តល់មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុភ្លាម ក្រោយពេលមុខចំណាយនីមួយៗត្រូវបានអនុវត្តចប់សព្វគ្រប់។ ក្នុងករណីមានភាពមិនច្បាស់លាស់ណាមួយ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាចស្នើឱ្យមានការបំភ្លឺបន្ថែម ឬចុះពិនិត្យដល់ការដ្ឋាន មុននឹងផ្តល់ថវិកាបំពេញឡើងវិញ។

**ប្រការ៣:** អង្គភាពជំនាញក្រោមឱវាទក្រសួងអភិវឌ្ឍន៍ជនបទ សំដៅដល់ នាយកដ្ឋានជំនាញ និងមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត ជាអ្នកទទួលបន្ទុកអនុវត្តការងារអន្តរាគមន៍ជួសជុលបន្ទាន់នេះ។ ហាមដាច់ខាតប្រគល់សិទ្ធិឱ្យក្រុមហ៊ុនឯកជនម៉ៅការអនុវត្តបន្ត លើកលែងតែក្នុងករណីមានការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈជាធរមាន។

**ប្រការ៤:** ទឹកប្រាក់អតិបរមាចំនួន ២០០ (ពីររយ) លានរៀល នឹងត្រូវអនុញ្ញាតឱ្យចំណាយសម្រាប់មុខសញ្ញាអន្តរាគមន៍ជួសជុលបន្ទាន់នីមួយៗ។ ក្នុងករណីដែលមានតម្រូវការចំណាយថវិកាច្រើនជាងនេះ ត្រូវមានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**ប្រការ៥:** ក្នុងករណីដែលពិនិត្យឃើញថារហូតដល់ដំណាច់ឆ្នាំ ថវិកាមិនអាចចំណាយអស់ ឥណទានថវិកាដែលនៅសល់អាចបង្វែរទៅប្រើប្រាស់សម្រាប់ការងារជួសជុល និងថែទាំផ្លូវជនបទផ្សេងទៀតដែលកំពុងមានតម្រូវការចាំបាច់ បន្ទាប់ពីមានការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៦:** សាច់ប្រាក់ដែលបានបើកផ្តល់ជាបន្តបន្ទាប់ក្នុងឆ្នាំ ហើយនៅសល់មិនបានចំណាយ ត្រូវបង់ចូលថវិកាជាតិវិញនាដំណាច់ឆ្នាំ តាមរូបភាពជាសំណោះចំណាយ។

**ប្រការ៧:** ថវិកាចំនួន ៥០% (ហាសិបភាគរយ) ដូចចែងក្នុង **ប្រការ២** សម្រាប់ឆ្នាំបន្ទាប់ នឹងត្រូវផ្តល់ជូន ក្រោយពីរបាយការណ៍ទូទាត់ចំណាយក្នុងឆ្នាំកន្លងទៅទាំងអស់ និងរបាយការណ៍ស្តីពីការបង់សំណេះចំណាយ ត្រូវបានផ្តល់មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ....៤៤៨.....សហវ.ប្រ.ក

**ប្រកាស**

**ស្ដីពី**

**ការលុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌ**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ១២១៣/ ១៣៩៣ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៣ ស្ដីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងលិខិតលេខ ២០០/១៦ គ.ម.ក. ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៦ របស់គណៈកម្មការមូលបត្រកម្ពុជា ស្ដីពីសំណើសុំផ្ដល់យោបល់ក្នុងការលុបឈ្មោះមន្ត្រីចំនួន ០១រូប ស្ថិតក្នុងក្របខ័ណ្ឌគណៈកម្មការមូលបត្រកម្ពុជា

**សម្រេច**

**ប្រការ១ .-**

ត្រូវបានលុបឈ្មោះលោក **ម៉ុកម៉ី មណ្ឌល** អត្តលេខ ១៦៨១២០០២៣៧ អនុប្រធាននាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ នៃគណៈកម្មការមូលបត្រកម្ពុជា ចេញពីក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចាប់ពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92 Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣៤២៧ ៧៩៨
Phone 855 - 23 724 664 Fax 855-23-427 798
mef_adm@yahoo.com

**ប្រការ២ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ១២៧ ឆ្នាំ២០១៦

បណ្ឌិត. **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...៥៦៣.....សហវ...ប្រក

**ប្រកាស**

**ស្តីពី**

**ការលុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌ**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញសេចក្តីសម្រេចលេខ ៥២ សសរ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០៥ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការកែសម្រួលប្រាក់ឧបត្ថម្ភគោលនយោបាយធានារ៉ាប់រងសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
- បានឃើញសារាចរណែនាំលេខ ០០២ សរណន.សអយ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៦ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា ស្តីពីការកែសម្រួលប្រាក់ឧបត្ថម្ភគោលនយោបាយធានារ៉ាប់រងសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
- យោងលិខិតលេខ ០២៧០/១៦ អគរ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៦ របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ស្តីពីសំណើសុំលុបឈ្មោះលោក **ផៃ ច័ន្ទសុវណ្ណ** ចេញពីក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមូលហេតុទទួលមរណភាព
- យោងលិខិត ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៦ របស់វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីសំណើសុំលុបឈ្មោះលោក **អ៊ាប វុទ្ធី** ចេញពីក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមូលហេតុទទួលមរណភាព



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92 Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣៤២៧ ៧៩៨
Phone 855 - 23 724 664 Fax 855-23-427 798
mef_adm@yahoo.com

## សម្រេច

**ប្រការ១ .-**

ត្រូវបានលុបឈ្មោះមន្ត្រីរាជការចំនួន០២នាក់ ចេញពីក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមូលហេតុបានទទួលមរណៈភាព ដូចមានរាយនាមខាងក្រោម ÷

១-លោក **ផៃ ចំនួសុខណ្ណា** អត្តលេខ ១៥៩០៣០០១៩៦ អនុប្រធានការិយាល័យគយនិងរដ្ឋាករត្រពាំងថ្លុង នៃសាខាគយនិងរដ្ឋាករខេត្តត្បូងឃ្មុំ នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ចាប់ពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦

២-លោក **អ៊ិច ទុទ្ធី** អត្តលេខ ១៦៧០២០០២៣៦ អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ នៃវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦។

**ប្រការ២ .-**

បៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំ នៃបៀវត្សរបស់អ្នកទទួលមរណភាព ត្រូវបង្វិលចូលថវិការដ្ឋវិញ ចាប់ពីថ្ងៃ ខែ ឆ្នាំ ដែលបានកំណត់លុបឈ្មោះចេញពីក្របខ័ណ្ឌ ។ ប្រាក់ឧបត្ថម្ភចំពោះលោក **ផៃ ចំនួសុវណ្ណា** និងលោក **អ៊ិច ទុទ្ធី** ត្រូវបានអនុវត្តតាមគោលការណ៍ច្បាប់ជាធរមាន ។

**ប្រការ៣ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកនៃវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ប្រធានសាខាគយនិងរដ្ឋាករខេត្តត្បូងឃ្មុំ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ០៣ ឆ្នាំ២០១៦

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- សាលាខេត្តត្បូងឃ្មុំ
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ២៦៦.........សហវ.ប្រក

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការតែងតាំងថ្នាក់ដារបើកផ្តល់សម្រាប់ឆ្នាំ២០១៦
## របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** **រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ន.ស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ២០ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA. Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ១.-**

ប្រាក់បៀវត្សមន្ត្រីរាជការ និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នឹងត្រូវបើកផ្តល់តាមរយៈ (ភ្នាក់ងារបើកផ្តល់) ។

**ប្រការ២.-**

ត្រូវបានតែងតាំងៈ

-លោក **ម៉ែន វណ្ណា** ឋានៈអនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ-គណនេយ្យ ជាភ្នាក់ងារបើកផ្តល់នៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

-កញ្ញា **សោម គារិទ្ធ** ឋានៈប្រធានការិយាល័យថវិកា ជាភ្នាក់ងារបើកផ្តល់ជំនួស ។

-លោក **ស៊ីម គឹមអ៊ីង** ឋានៈអនុប្រធានការិយាល័យថវិកា ជាភ្នាក់ងារបើកផ្តល់ជំនួស ។

**ប្រការ៣.-**

លោក ម៉ែន វណ្ណា កញ្ញា សោម គារិទ្ធ និងលោក ស៊ីម គឹមអ៊ីង ត្រូវបានអនុញ្ញាតិឱ្យបើកគណនីប្រាក់បញ្ញើនៅអគ្គនាយកដ្ឋានរតនាគារជាតិ ដើម្បីទទួលមូលនិធិសម្រាប់យកទៅបើកបៀវត្ស និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌ជូនមន្ត្រីរាជការ ។

**ប្រការ៤.-**

បែបបទនៃការអនុវត្តបើកផ្តល់បៀវត្ស និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌ ត្រូវបានកំណត់ដោយសេចក្តីប្រកាសណែនាំជាក្រោយ ។

**ប្រការ៥.-**

ភ្នាក់ងារបើកផ្តល់ត្រូវទទួលខុសត្រូវផ្ទាល់ចំពោះប្រាក់កាស និងមូលនិធិដែលបានទទួល ដើម្បីយកទៅធ្វើការបើកផ្តល់ជូនមន្ត្រីរាជការ ។

**ប្រការ៦.-**

សេចក្តីសម្រេចទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៧.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា ព្រមទាំងប្រធានគ្រប់អង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

បណ្ឌិត. **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួលៈ**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ ៧
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ [illegible] សហវ.ប្រក

# ប្រកាសអន្តរក្រសួង
# ស្តីពី
# ការបង្កើតវិជ្ជទេយ្យបុរេប្រទានសម្រាប់ឆ្នាំ ២០១៦
# របស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា (ក្រសួងធនធានទឹក និងឧតុនិយម)

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**　　**រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម**
**និងជាប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ន.ស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦
- បានឃើញអនុក្រឹត្យលេខ ៨៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៩៧ អនក្រ.បក ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ ២០១២ ស្តីពីកែសម្រួលអនុក្រឹត្យលេខ១០ អនក្រ.បក ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការព្រឹត្តទៅរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បកចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាម ក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់អោយអនុវត្តន៍ចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់អោយអនុវត្តន៍មាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមវិជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ២០១៥ ស្តីពីការកែសម្រួលប្រការ ៤ ប្រការ ៥ ប្រការ ១៤ និងប្រការ ១៧ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៤ ស្តីពីនីតិវិធីចំណាយតាមវិជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- យោងតាមតម្រូវការចាំបាច់ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបច្ចុប្បន្ន
- យោងតាមតម្រូវការចាំបាច់របស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា (ក្រសួងធនធានទឹក និងឧតុនិយម)

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St. 92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ័ : ៨៥៥-២៣-៧២៤ ៦៦៤  ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664    Fax : 855-23-427 798

## សម្រេច

**ប្រការ ១:**

ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទាន ជំពូក៦៥ នៅគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា (ក្រសួងធនធានទឹក និងឧតុនិយម) សម្រាប់មុខសញ្ញាចំណាយដូចមានចែងក្នុងប្រការ ៥ ថ្មី នៃប្រកាសលេខ ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ២០១៥ ស្តីពីការកែសម្រួលប្រការ ៤ ប្រការ ៥ ប្រការ ១៤ និងប្រការ ១៧ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ ។

តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ ២:**

ចំនួនទឹកប្រាក់មួយជុំបង្វិល នៃរជ្ជទេយ្យបុរេប្រទាន ត្រូវកំណត់ក្នុងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ។

**ប្រការ ៣:**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៤:**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន ប្រធាននាយកដ្ឋាន ប្រធានអង្គភាពទទួលបន្ទុករដ្ឋបាល និងហិរញ្ញវត្ថុរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តន៍ប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែមេសា ឆ្នាំ ២០១៦

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

បណ្ឌិត. **អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម**
**និងជាប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា**

**លឹម គានហោ**

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងធនធានទឹក និងឧតុនិយម**
**គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា**

## តារាងឧបសម្ព័ន្ធវិភាជន៍ថវិកាផ្តល់ជូនទេយ្យបុរេប្រទានពិសេសឆ្នាំ២០១៦ របស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៦ | ឥណទានដែលជ្រើសរើស | ឥណទានវិភាជន៍ជូនទេយ្យឆ្នាំ២០១៦ | ឥណទានទូទាត់ធម្មតា | ឥណទានទំហំបង្វិលជូនទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| 65 | | | ឧបត្ថម្ភកធន | 7,746,000,000 ៛ | | | | | |
| | 6502 | | ឧបត្ថម្ភដល់អង្គការសាធារណៈ | 5,500,000,000 ៛ | | | | | |
| | | 65026 | ឧបត្ថម្ភកធនដល់អង្គភាពដែលមានលក្ខណៈរដ្ឋបាល | 5,500,000,000 ៛ | 1,500,000,000 ៛ | 324,000,000 ៛ | 1,176,000,000 ៛ | 81,000,000 ៛ | 18% |
| | | សរុប | | | | | 1,176,000,000 ៛ | 81,000,000 ៛ | |

បានឃើញ និង ពិនិត្យត្រឹមត្រូវ
ថ្ងៃទី[illegible] ខែ [illegible] ឆ្នាំ ២០១៦
អគ្គនាយក
អគ្គនាយកដ្ឋានរតនាគារជាតិ
អគ្គនាយករង
ម៉ិញ បានសុវណ្ណអាធិច្ចាសីលា

បានឃើញ និង ពិនិត្យត្រឹមត្រូវ
ថ្ងៃទី[illegible] ខែ [illegible] ឆ្នាំ ២០១៦
អគ្គនាយក
អគ្គនាយកដ្ឋានថវិកា
អ៊ុក សុវត្ថារ៉ា

បានឃើញ និងឯកភាព
ថ្ងៃទី[illegible] ខែមេសា ឆ្នាំ ២០១៦
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

បានឃើញ និង ពិនិត្យត្រឹមត្រូវ
ថ្ងៃទី[illegible] ខែ [illegible] ឆ្នាំ ២០១៦
អគ្គលេខាធិការ
អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
តែ ណាវុធ

ថ្ងៃទី[illegible] ខែ [illegible] ឆ្នាំ ២០១៦
រដ្ឋទេយ្យករបុរេប្រទាន
ស្វាយ_សុភី

បានឃើញ និងឯកភាព
ថ្ងៃទី[illegible] ខែ [illegible] ឆ្នាំ ២០១៦
រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម
និងជាប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
លឹម_គានហោ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ៤៦៨..........សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែមេសា ឆ្នាំ ២០១៦

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការតែងតាំងថ្នាក់ងារបើកផ្តល់ សម្រាប់បើកប្រាក់បៀវត្សរ៍ និងប្រាក់អន្តរាគមន៍ ក្នុងវិស័យសង្គមកិច្ចនិងវប្បធម៌ ជូនមន្ត្រីរាជការនៅក្រសួងមហាផ្ទៃ ផ្នែករដ្ឋបាលទូទៅ

**រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/ រកត/ ០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែម សមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ន.ស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែ វិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែ វិច្ឆិកាឆ្នាំ១៩៩៦ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ១៨៩សហវ.ប្រក ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឲ្យអនុវត្តចំណាត់

ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី ០៤ ខែ មិនា ឆ្នាំ២០១៣ ស្តីពីការដាក់ឲ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១:** -

ប្រាក់បៀវត្សរ៍មន្ត្រីរាជការ និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងត្រូវ បើក ផ្តល់តាមរយៈភ្នាក់ងារបើកផ្តល់ ។

**ប្រការ២:** -

ត្រូវបានតែងតាំងភ្នាក់ងារបើកផ្តល់ និងភ្នាក់ងារបើកផ្តល់ជំនួស របស់ក្រសួងមហាផ្ទៃ ផ្នែករដ្ឋបាលទូទៅដូចមានសមាសភាពខាងក្រោម៖

- លោក **ញ៉ាញ់ ដានី** ប្រធានការិយាល័យគណនេយ្យ ជាភ្នាក់ងារបើកផ្តល់
- លោកស្រី **សូភាន សុគន្ធារី** មន្ត្រីការិយាល័យគណនេយ្យ ជាភ្នាក់ងារបើកផ្តល់ជំនួស

**ប្រការ៣:** -

លោក **ញ៉ាញ់ ដានី** ជាភ្នាក់ងារបើកផ្តល់លោកស្រី **សូភាន សុគន្ធារី** ជាភ្នាក់ងារបើកផ្តល់ជំនួសត្រូវបានអនុញ្ញាតឲ្យបើកគណនីប្រាក់បញ្ញើនៅអគ្គនាយកដ្ឋានរតនាគារជាតិដើម្បីទទួលមូលនិធិសម្រាប់យកទៅបើកប្រាក់បៀវត្សរ៍ និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌ជូនមន្ត្រីរាជការ ។

**ប្រការ៤:** -

បែបបទនៃការអនុវត្តបើកផ្តល់បៀវត្សរ៍ និងប្រាក់អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌ត្រូវបានកំណត់ដោយសេចក្តីណែនាំជាក្រោយ ។

**ប្រការ៥:** -

ភ្នាក់ងារបើកផ្តល់ត្រូវទទួលខុសត្រូវចំពោះប្រាក់កាសនិងមូលនិធិដែលបានទទួលដើម្បីយកទៅធ្វើការបើកផ្តល់ជូនមន្ត្រីរាជការ ។

**ប្រការ៦:** -

សេចក្តីសម្រេចទាំងឡាយណា ដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ៧:** -

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ ព្រមទាំងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ផ្នែករដ្ឋបាលទូទៅ ដូចមានឈ្មោះចែងក្នុងប្រការ ២ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៤៦៥ ..........សហវ.ប្រក

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការតែងតាំងរដ្ឋលេខាធិការបុរេប្រទានរបស់ក្រសួងមហាផ្ទៃ ផ្នែករដ្ឋបាលទូទៅ

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែម សមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ន.ស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែ វិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែ វិច្ឆិកាឆ្នាំ១៩៩៦ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ១៨៩សហវ.ប្រក ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឲ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិកាបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី ០៤ ខែ មិនា ឆ្នាំ២០១៣ ស្តីពីការដាក់ឲ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរដ្ឋលេខាបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ ៨២៩ សហវ.ប្រក ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥

ប្រការ១៤ ប្រការ ១៦ និងប្រការ ១៧ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន

- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ផ្នែករដ្ឋបាលទូទៅ

## សម្រេច

**ប្រការ១:** .–

ត្រូវបានតែងតាំងរជ្ជទេយ្យករបុរេប្រទានរបស់ក្រសួងមហាផ្ទៃ ផ្នែករដ្ឋបាលទូទៅ ដូចមានសមាសភាពខាងក្រោម៖

- លោក **ញ៉ាញ់ ដានី** ឲ្យទទួលបន្ទុកការងារជា "រជ្ជទេយ្យករបុរេប្រទាន" នៅក្រសួងមហាផ្ទៃ ផ្នែករដ្ឋបាលទូទៅ
- លោក **អុំ ពិសិដ្ឋ** ឲ្យទទួលបន្ទុកការងារជា " រជ្ជទេយ្យករបុរេប្រទានរង " នៅក្រសួងមហាផ្ទៃ ផ្នែករដ្ឋបាលទូទៅ

**ប្រការ២:** .–

សេចក្តីសម្រេចទាំងឡាយណា ដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ៣:** .–

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ ព្រមទាំងប្រធានគ្រប់អង្គភាពពាក់ព័ន្ធ ទាំងអស់ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ផ្នែករដ្ឋបាលទូទៅ ដូចមានឈ្មោះចែងក្នុងប្រការ ១ មានភារកិច្ចទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែមេសា ឆ្នាំ ២០១៦

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ១៨៤៤..ឧស.ក.វ.ក.០៣

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០១៦

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំការអនុញ្ញាតបង្កើតរោងចក្រ ផលិតគ្រឿងបន្សំស្បែកជើង ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៦ របស់ក្រុមហ៊ុន ស៊ូ ហ្គោល លីត ហូលឌីង។

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន ស៊ូ ហ្គោល លីត ហូលឌីង (SHOES GOLD LITE HOLDING CO., LTD.) តំណាងដោយ លោក **CHAN, YU-JEN** បង្កើតរោងចក្រ ផលិតគ្រឿងបន្សំស្បែកជើង ដែលមានទីតាំងស្ថិតនៅ ភូមិអង្គសុគន្ធា ឃុំមហាឫស្សី ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| គ្រឿងបន្សំស្បែកជើង | ១៥២០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ ៖** " រោងចក្រផលិតគ្រឿងបន្សំស្បែកជើង ស៊ូ ហ្គោល លីត ហូលឌីង "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួល ហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាម មាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការ ជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពី វិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពី វិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹង វិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកំពង់ស្ពឺ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម
រដ្ឋលេខាធិការ

ហេង សុខគង់

**ចម្លងជូន៖**
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងពាណិជ្ជកម្ម
- -ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- -ក្រសួងបរិស្ថាន
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- -ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- -សាលាខេត្តកំពង់ស្ពឺ
  "ដើម្បីជូនជ្រាប"
- -ដូចប្រការ១៤ "ដើម្បីអនុវត្ត"
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : [illegible] ឧស.[illegible].០៣

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ មិនា ឆ្នាំ២០១៦

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តី ពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំការអនុញ្ញាតបង្កើតរោងចក្រ ផលិតគ្រឿងបន្សំសម្លៀកបំពាក់ របស់ក្រុមហ៊ុន មីលេនៀម អេកសេសីរី មេញូហ្វេកឈ័រ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥។

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន មីលេនៀម អេកសេសីរី មេញូហ្វេកឈ័រ (MILLENNIUM ACCESSORY MANUFACTURE CO., LTD.) តំណាងដោយ លោក ហ្វាន់ វ៉ីមីង បង្កើតរោងចក្រ ផលិតគ្រឿងបន្សំសម្លៀកបំពាក់ ដែលមានទីតាំងស្ថិតនៅ ភូមិព្រៃខ្វាវ ឃុំកាកោះ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
|---|---|
| គ្រឿងបន្សំសម្លៀកបំពាក់ | ១៤១០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ** ៖ " រោងចក្រផលិតគ្រឿងបន្សំសម្លៀកបំពាក់ មីលេនៀម អេកសេសឺរី មេញហ្វូហ្វេកឈ័រ "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់ នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

__ប្រការ១១៖__ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រង រោងចក្រ និងសិប្បកម្ម។

__ប្រការ១២៖__ លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

__ប្រការ១៣៖__ ម្ចាស់រោងចក្រត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

__ប្រការ១៤៖__ អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកំពង់ស្ពឺ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន។

__ប្រការ១៥៖__ ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**រដ្ឋលេខាធិការ**

**ហេង សុខគង់**

__ចម្លងជូន៖__
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-សាលាខេត្តកំពង់ស្ពឺ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

លេខ÷...១៥៥..... ប្រក/ ដនស./**មផ**

## ប្រកាសអន្តរក្រសួង

## ស្តីពី

## ការកែសម្រួលប្រការ ៩ នៃប្រកាសអន្តរក្រសួងលេខ ២១៥ ប្រក/ដនស.មផ ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៥ ស្តីពីតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ សង្កាត់ ក្នុងការចុះបញ្ជីដីធ្លី

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- បានឃើញអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០០២ ស្តីពីការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ
- យោងតាមការចាំបាច់របស់ក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ✓

អាសយដ្ឋាន : ដីឡូត៍លេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ (855) 23 215 660 / 23 215 277 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

## សម្រេច

**ប្រការមួយ .**

ប្រការ ៩ នៃប្រកាសអន្តរក្រសួងលេខ ២១៥ ប្រក/ជនស.មជ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ ២០០៥ ស្តីពីតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលឃុំ សង្កាត់ ក្នុងការចុះបញ្ជីដីធ្លី ត្រូវបានកែសម្រួលដូចតទៅ÷

**ប្រការ ៩ . ថ្មី**

មេឃុំ ចៅសង្កាត់ ជាអ្នកបញ្ជាក់លើលិខិតសញ្ញាផ្សេងៗ ដូចជា លិខិតលក់ផ្តាច់ អំណោយផ្តាច់ កិច្ចសន្យាបញ្ចាំ ដាក់ធានា ហ៊ីប៉ូតែក កិច្ចសន្យាជួលរយៈពេលវែង កិច្ចសន្យាបង្កើតសេវភាព ផលុបភោគ អាស្រ័យលើការព្រមព្រៀងរបស់គូភាគី ។ ក្នុងការបញ្ជាក់ មេឃុំ ចៅសង្កាត់ត្រូវយកចិត្តទុកដាក់ និងទទួលខុសត្រូវលើ ÷

- អត្តសញ្ញាណអចលនវត្ថុ ដែលជាកម្មវត្ថុនៃលិខិតកិច្ចសន្យា និង
- អត្តសញ្ញាណគូភាគីនៃកិច្ចសន្យា ។

**ប្រការពីរ .**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការបី .**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល គ្រប់ប្រធានអង្គភាពក្រោមឱវាទក្រសួងមហាផ្ទៃ នាយកខុទ្ទកាល័យ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន គ្រប់ប្រធានអង្គភាពក្រោមឱវាទក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គ្រប់អភិបាលរាជធានី ខេត្ត គ្រប់ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត គ្រប់អភិបាលក្រុង ស្រុក ខណ្ឌ គ្រប់ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ គ្រប់ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែមិថុនា គ.ស. ២០១៦

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

<u>កន្លែងទទួល÷</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ដូចប្រការបី
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ